**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# សន្តិកម្មតាមច្បាប់

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ: **កញ្ញា លី ដាលីហ្សា**

**កញ្ញា អ៊ា វិល្លីន្និច្ច**

សាស្ត្រាចារ្យណែនាំ

លោក **ឃឹម ឧត្តម**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ **លី ដាលីហ្សា** និង **អ៊ា វិល្លីនិច្ច** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី២ ថ្នាក់ L4A3 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងសម្តែងការគោរពចំពោះ អ្នកម្តាយ និង លោកឪពុកដែលមានគុណបានផ្តល់កំណើត និងបានខិតខំប្រឹងប្រែងចិញ្ចឹម បីបាច់រក្សា អប់រំទូន្មានប្រៀនប្រដៅព្រមទាំងបានខិតខំប្រឹងប្រែងពុះពារគ្រប់ឧបសគ្គ ដើម្បីផ្គត់ផ្គង់កូនគ្រប់ផ្នែកនៃការរស់នៅជាពិសេសបានបញ្ជូនកូនឱ្យក្រេបយកចំណេះដឹងដែលធ្វើឱ្យកូនបានក្លាយជាមនុស្សម្នាក់ដែលសង្គម និងគ្រួសារទទួលស្គាល់ និងផ្តល់តម្លៃទទួលបានការគោរពស្រឡាញ់ពីមនុស្សជុំវិញខ្លួន។

លើសពីនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណជូនចំពោះលោកគ្រូ **ឃឹម ឧត្តម** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំសរសេរសារណា និងណែនាំផ្តល់ជាគំនិតល្អៗក្នុងការតាក់តែងសរសេរសារណាមួយនេះ តាំងពីចាប់ផ្តើមរហូតបានបញ្ចប់យ៉ាងជោគជ័យ។

ជាចុងក្រោយ យើងខ្ញុំសូមគោរពដឹងគុណ និងថ្លែងអំណរគុណដល់ មាតា បិតា និងលោកគ្រូសូមជួបប្រទះ សេចក្តីសុខ សំណាងល្អ និង ព្រមទាំងពុទ្ធិពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីបានបញ្ចប់ការសិក្សាផ្នែកនីតិសាស្ត្រអស់រយៈពេល ៤ ឆ្នាំមកនេះសាកលវិទ្យាល័យបាន តម្រូវឱ្យនិស្សិតធ្វើការសរសេរសារណា ឬរបាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាក្នុងគោលបំណងចង់ឱ្យ និស្សិតសិក្សាស្វែងយល់បន្ថែមនូវអ្វីដែលបានសិក្សាកន្លងមក។

ដោយហេតុនេះយើងខ្ញុំបានជ្រើសរើសប្រធានបទមួយដែលមានចំណងជើងថា "**សន្តតិកម្មតាម ច្បាប់**"មកធ្វើការសិក្សាស្រាវជ្រាវបន្ថែមឱ្យបានកាន់តែដឹងច្បាស់អំពីការបែងចែកមត៌កតាមច្បាប់ថាតើការ បើកសន្តតិកម្មនឹងចាប់នៅពេលណាតើត្រូវមានលក្ខណៈសម្បត្តិយ៉ាងណាខ្លះទើបអាចក្លាយជាសន្តតិជន ជាពិសេសអំពីការកែសម្រួលចំណែកមត៌ក។ បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវហើយយើងក៏បានកាន់ តែយល់ច្បាស់ថា សន្តតិកម្មតាមច្បាប់ពិតជាបានផ្តល់ផលប្រយោជន៍ជាច្រើនក្នុងការបែងចែកមត៌ករបស់ មតកជន ជាពិសេសនៅពេលមតកជនបានទទួលមរណភាពដោយមិនបានបន្សល់ទុកនូវបណ្តាំមត៌ក តាមឆន្ទៈ។ សន្តតិកម្មតាមច្បាប់បានជួយសម្រួល និង ទប់ស្កាត់វិវាទរវាងសមាជិកគ្រួសារបងប្អូនសាច់ ញាតិរបស់មតកជនដោយសន្តតិកម្មតាមច្បាប់បានកំណត់ពីជនដែលមានសិទ្ធិតាមច្បាប់ទៅលើចំណែក មត៌ករបស់មតកជន។

ជាចុងក្រោយ យើងខ្ញុំសង្ឃឹមថាកិច្ចការស្រាវជ្រាវមួយនេះនឹងអាចផ្តល់ជាប្រយោជន៍ទៅកាន់មិត្តៗ អ្នកសិក្សាក្នុងការសិក្សានិងបានស្វែងយល់ជាងមុនអំពីប្រធានបទមួយនេះ។ហើយយើងខ្ញុំក៏សូមន្តីអភ័យ ទោសទុកជាមុនរាល់ចំណុចខ្វះខាត និង កំហុសខុសឆ្គងដែលកើតមានឡើងទៅលើអត្ថន័យខ្លឹមសារ និង អក្ខរាវិរុទ្ធដោយអចេតនាណាមួយ យើងខ្ញុំរីករាយនឹងទទួលយកនូវមតិរិះគន់ក្នុងន័យស្ថាបនាដើម្បីធ្វើការ កែតម្រូវ និង បំពេញចំណុចខ្វះខាត។

# មាតិកា

ទំព័រ


សេចក្តីផ្តើម ........................................................................................................១

## ជំពូកទី១៖ លក្ខខណ្ឌទូទៅនៃសន្តតិកម្ម

ផ្នែកទី១៖ សញ្ញាណនៃសន្តតិកម្ម .........................................................................៣

១.១. ប្រភេទនៃសន្តតិកម្ម ...................................................................................៣

១.២. ការកើតឡើងនៃសន្តតិកម្ម ........................................................................... ៣

១.២.១.កាលបរិច្ឆេទចាប់ផ្តើមធ្វើសន្តតិកម្ម ..........................................................៣

១.២.២.ទីកន្លែងចាប់ផ្តើមធ្វើសន្តតិកម្ម .............................................................. ៤

ផ្នែកទី២៖ លក្ខណៈសម្បត្តិនៃសន្តតិជន ............................................................... ៥

២.១.បុគ្គលដែលមានលក្ខណៈសម្បត្តិជាសន្តតិជន .................................................. ៥

២.១.១. រូបវន្តបុគ្គល ....................................................................................... ៥

២.១.២. ទារកក្នុងគភ៌ .......................................................................................៥

២.២.បុគ្គលដែលមិនអាចទទួលសន្តតិកម្ម ............................................................. ៦

២.២.១. ករណីអភ័ព្វបុគ្គល ................................................................................ ៦

២.២.២.ការផ្តាច់មត៌កពីសន្តតិជន ..................................................................... ៧

២.៣.ករណីពិសេសចំពោះជនជាតិបរទេស ...............................................................៧

## ជំពូកទី២៖ បញ្ញត្តិនៃសន្តតិកម្មតាមច្បាប់

ផ្នែកទី១៖ សន្តិជនដែលច្បាប់បានកំណត់.............................................................៩

១.១. លំដាប់នៃសន្តតិជន ......................................................................................៩

១.១.១. សន្តិជនលំដាប់ទី១ ..................................................................................៩

១.១.២. សន្តិជនលំដាប់ទី២ ................................................................................១០

១.១.៣. សន្តិជនលំដាប់ទី៣................................................................................. ១១

១.២. សន្តតិជនជានិច្ច ........................................................................................១១

១.៣. សន្តតិជនជំនួស .........................................................................................១២

ផ្នែកទី២៖ ការបែងចែកមត៌កទៅតាមចំណែករបស់សន្តតិជន .....................................១២

២.១. ករណីសន្តតិជនមានតែបញ្ញាញាតិ ................................................................១៣

២.២. ករណីសន្តតិជនមានតែបុព្វញាតិ ...................................................................១៤

២.៣. ករណីសន្តតិជនមានតែបងប្អូនបង្កើត ..............................................................១៥

**២.៤. ករណីសន្តតិជនមានសហព័ទ្ធ រួមជាមួយនឹងញាតិ** ....................................១៧
២.៤.១. ករណីសន្តតិជនមានតែសហព័ទ្ធ ..............................................................១៧
២.៤.២. ករណីសន្តតិជនជាសហព័ទ្ធរួមជាមួយបច្ឆាញាតិ .......................................... ១៧
២.៤.៣. ករណីសន្តតិជនជាសហព័ទ្ធរួមជាមួយបុព្វញាតិ ..........................................១៧
២.៤.៤. ករណីសន្តតិជនជាសហព័ទ្ធរួមជាមួយសាខាញាតិ .......................................១៨
**ផ្នែកទី៣៖ ការសម្រួលចំណែកមត៌ក** ...................................................................១៩
**៣.១. ការសម្រួលចំណែកមត៌ក** ..................................................................................១៩
**៣.២. ផលប្រយោជន៍ពិសេស** ......................................................................................១៩
៣.២.១. ករណីផលប្រយោជន៍ពិសេសមានតម្លៃតិចជាងចំណែកមត៌ក .............................២០
៣.២.២. ករណីផលប្រយោជន៍ពិសេសមានតម្លៃស្មើរនឹងចំណែកមត៌ក ...........................២០
៣.២.៣. ករណីផលប្រយោជន៍ពិសេសមានតម្លៃច្រើនជាងចំណែកមត៌ក ..........................២១
៣.២.៤. តម្លៃប្រទានកម្ម ......................................................................................២១
**៣.៣. ភាគនៃវិភាគទាន** ...........................................................................................២២
**៣.៤. ភាពបម្រុង** ......................................................................................................២៥
៣.៤.១ ទ្រព្យជាមូលដ្ឋានក្នុងការគណនាភាគបម្រុង ................................................២៥
៣.៤.២ អ្នកមានសិទ្ធិលើភាគបម្រុង ......................................................................២៥
៣.៤.៣. ការគណនាភាគបម្រុង ................................................................................២៦
៣.៤.៤. ការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយ ...........................................................២៧
**ផ្នែកទី៤៖ ការយល់ព្រមទទួល ឬបោះបង់ចំណែកសន្តតិកម្ម** ...............................២៨
**៤.១. ការយល់ព្រមទទួលសន្តតិកម្ម** ........................................................................២៩
៤.១.១. ការយល់ព្រមទាំងស្រុង ..............................................................................២៩
៤.១.២. ការយល់ព្រមមានកម្រិត ............................................................................២៩
**៤.២. ការបោះបង់សន្តតិកម្ម** ....................................................................................៣០
**សន្និដ្ឋាន** ..........................................................................................................៣១
**អនុសាសន៍**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ការកើត ចាស់ ឈឺ ស្លាប់ គឺជារបបធម្មជាតិមួយដែលយើងមិនអាចកំណត់បាននោះឡើយ។ នៅក្នុងឆាកជីវិតរបស់មនុស្សម្នាក់ៗយើងគង់តែជួបប្រទះនូវការបាត់បង់មនុស្សជាទីស្រឡាញ់ ឬមនុស្សដែលនៅជុំវិញខ្លួន យើង។ ដោយយើងខ្ញុំឃើញថា នៅក្នុងទិដ្ឋភាពសង្គមតែងតែជួបនូវវិវាទរវាងញាតិចំពោះការបែងចែកទ្រព្យសម្បត្តិរបស់មតកជនក្រោយពេលដែលមតកជនបានទទួលមរណៈភាពហើយ ជាពិសេសភាពស្មុគស្មាញកាន់តែកើតមានឡើង នៅពេលដែលមតកជនមិនបានបង្ហាញឆន្ទៈក្នុងការបែងចែកទ្រព្យរបស់ខ្លួនមុនពេលដែលទទួលមរណភាព។ បញ្ញត្តិនៃច្បាប់ជុំវិញការទទួលបន្តរនូវមត៌កគឺមានលក្ខណៈខុសៗគ្នាទៅតាមប្រទេសនីមួយៗដោយសន្តតិកម្មតាមច្បាប់មានលក្ខណៈខុសពីសន្តតិកម្មដោយមតកសាសន៍ត្រង់ថាសន្តតិកម្មតាមច្បាប់គឺ ជាបញ្ញត្តិនៃច្បាប់ដែលបានកំណត់ពីដំណើរការនៃការទទួលមត៌កក្នុងករណីដែលមកមតជនគ្មានឆន្ទៈត្រឹមត្រូវក្នុងការបែងចែកទ្រព្យសម្បត្តិដែលខ្លួនបានបន្សល់ទុក។ បញ្ញត្តិនៃច្បាប់នេះគឺបម្រើនូវអត្ថប្រយោជន៍ជាច្រើនដូចជា ផ្តល់នូវសំណាញ់សុវត្ថិភាពទៅដល់សន្តតិជនស្របច្បាប់ធានានូវការបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ និងអាចព្យាករណ៍បាននូវចំណែកមត៌កដែលសន្តតិជននឹងត្រូវទទួលបាន នៅពេលដែលមតកជនមិនបានបញ្ជាក់ពីបំណងប្រាថ្នារបស់ខ្លួនឱ្យបានច្បាស់លាស់។ បញ្ញត្តិនៃសន្តតិកម្មតាមច្បាប់នេះត្រូវបានដាក់បញ្ចូលក្នុងក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧នៅក្នុងគន្ថីទី៨ ដែលផ្តល់នូវបញ្ញត្តិច្បាស់លាស់សម្រាប់ការបែងចែកមមត៌ក ក៏ដូចជាសិទ្ធិនិងកាតព្វកិច្ចរបស់សន្តតិជន។ បញ្ញត្តិនៃច្បាប់ត្រូវបានយកមកប្រើប្រាស់នៅពេលដែលភាពស្មុគស្មាញលេចឡើងនៅក្នុងសេណារីយ៉ូណាមួយ។

នៅក្នុងអត្ថបទស្រាវជ្រាវខាងក្រោម យើងខ្ញុំនឹងធ្វើការសិក្សាទៅលើបញ្ញត្តិនៃច្បាប់នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ដែលកំណត់អំពីរបបសន្តតិកម្មនៅក្នុងប្រទេសកម្ពុជាដោយយើងធ្វើការផ្តោតសំខាន់ចំពោះតែ "សន្តតិកម្មតាមច្បាប់"។ យើងខ្ញុំនឹងធ្វើការបកស្រាយអំពីគោលការណ៍នៃរបបសន្តតិកម្មបុគ្គលដែលមានលក្ខណៈសម្បត្តិជាសន្តតិជន បទបញ្ញត្តិនៃសន្តតិកម្មតាមច្បាប់ និងការអនុវត្តទៅលើសិទ្ធិរបស់សន្តតិជន ក៏ដូចជាភាពស្មុគស្មាញនៃរបបសន្តតិកម្មនេះ។

នៅក្នុងអត្ថបទខាងក្រោមនេះ មានគោលបំណងក្នុងការបកស្រាយនូវបញ្ញត្តិនៃច្បាប់ស្វែងរកភាពស្មុគស្មាញទាំងនេះដោយផ្តល់នូវការពន្យល់ និង សង្ខេបអំពីបទបញ្ញត្តិនៃសន្តតិកម្មតាមច្បាប់នៃប្រទេស

កម្ពុជា។ យើងខ្ញុំនឹងធ្វើការបកស្រាយកាន់តែស៊ីជម្រៅទៅលើបទបញ្ញត្តិផ្លូវច្បាប់ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជាវិភាគករណីសិក្សាដើម្បីបង្ហាញពីការអនុវត្ត និង ស្វែងរកបញ្ហាប្រឈមដែលអាចកើតឡើងក្នុងស្ថានភាពជាក់លាក់។ លើសពីនេះអត្ថបទខាងក្រោមនេះនឹងពិចារណាអំពីបរិបទវប្បធម៌ជុំវិញមត៌កក្នុងប្រទេសកម្ពុជាដោយពិនិត្យមើលថាតើ ជំនឿ និង ទំនៀមទម្លាប់ប្រពៃណីអាចជះឥទ្ធិពលដល់សក្តានុពលនៃរបបសន្តិកម្មតាមច្បាប់យ៉ាងដូចម្តេច។ តាមរយៈការសិក្សាស្រាវជ្រាវអំពីសន្តតិកម្មតាមច្បាប់នៅក្នុងប្រទេសកម្ពុជា យើងខ្ញុំសង្ឃឹមថាឯកសារនេះនឹងបម្រើជាធនធានដ៏មានតម្លៃសម្រាប់អ្នកជំនាញផ្នែកច្បាប់ បុគ្គលដែលមានបំណងស្វែងយល់ពីរបបនៃសន្តតិកម្មតាមច្បាប់ និងអ្នកដែលចាប់អារម្មណ៍ក្នុងការយល់ដឹង អំពីច្បាប់ និងប្រពៃណីរបស់កម្ពុជា។

ដើម្បីបកស្រាយអំពីប្រធានបទ *"**សន្តតិកម្មតាមច្បាប់**"* ឱ្យបានក្បោះក្បាយស៊ីជម្រៅ និង ច្បាស់លាស់យើងខ្ញុំសូមធ្វើការបែងចែកការសិក្សាស្រាវជ្រាវដូចខាងក្រោម៖

**ជំពូកទី១៖ លក្ខខណ្ឌទូទៅនៃសន្តតិកម្ម**

**ជំពូកទី២៖ បញ្ញត្តិនៃសន្តតិកម្មតាមច្បាប់**

# ជំពូកទី១
# លក្ខខណ្ឌទូទៅនៃសន្តិកម្ម

# ជំពូកទី១៖ លក្ខខណ្ឌទូទៅនៃសន្តតិកម្ម

## ផ្នែកទី១៖ សញ្ញាណគតិយុត្តនៃសន្តតិកម្ម

## ១.១. ប្រភេទនៃសន្តតិកម្ម

ពាក្យថា "**សន្តតិកម្ម**" មានន័យថាជាការផ្ទេរនូវសិទ្ធិ និង ករណីយកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ ឬ ច្រើននាក់តាមឆន្ទៈ ឬ តាមច្បាប់។[1] ដោយឡែកផ្អែកតាមមាត្រា ១១៤៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានចែងថាសន្តតិកម្មដែលផ្អែកតាមឆន្ទៈរបស់មតកជន (បណ្តាំមត៌ក) ហៅថា"**សន្តតិកម្មមានបណ្តាំ**"។ រីឯសន្តតិកម្មទាំងឡាយណាដែលធ្វើឡើងតាមបញ្ញត្តិច្បាប់ហៅថា"**សន្តតិកម្មតាមច្បាប់**"។

នៅពេលដែលមតកជនបានបង្ហាញឆន្ទៈក្នុងការបែងចែកមរត៌ករបស់ខ្លួន នៅអំឡុងពេលដែលជននោះនៅរស់ដោយបន្សល់ទុកនូវបណ្តាំជាដើម នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ទទួលស្គាល់នូវការបែងចែកតាមបណ្តាំមត៌កតែនៅក្នុងករណីដែលបណ្តាំនោះធ្វើឡើងត្រឹមត្រូវទៅតាមទម្រង់ និង លក្ខខណ្ឌដែលច្បាប់បានកំណត់ប៉ុណ្ណោះ។ នៅក្នុងកាលៈទេសៈដែលមតកជនមិនបានបន្សល់ទុកនូវបណ្តាំនោះទេជាស្វ័យប្រវត្តិសន្តតិកម្មនឹងត្រូវអនុវត្តតាមបញ្ញត្តិនៃច្បាប់។ យើងអាចធ្វើការសន្និដ្ឋានបានថាសន្តតិកម្មមានបណ្តាំគឺ ជាការបែងចែកមត៌កទៅឱ្យសន្តតិជនទៅតាមឆន្ទៈរបស់មតកជន ដែលធ្វើឡើងទៅតាមទម្រង់នៃមតកសាសន៍។ រីឯសន្តតិកម្មតាមច្បាប់ គឺជាការបែងចែកមត៌កទៅឱ្យសន្តតិជន ទៅតាមចំណែកនិងនីតិវិធីដែលបានកំណត់ដោយច្បាប់។

មូលហេតុដែលមត៌កត្រូវធ្វើការបែងចែកទៅតាមច្បាប់ ព្រោះមតកជនមិនបានបង្ហាញឆន្ទៈក្នុងការបែងចែកមត៌ករបស់ខ្លួននៅពេលដែលនៅរស់ ឬមិនបានបន្សល់ទុកនូវបណ្តាំមត៌ក ឬបណ្តាំមត៌កត្រូវបានលុបចោលដោយបណ្តាំមត៌កនោះបានធ្វើខុសពីទម្រង់ដែលច្បាប់បានកំណត់ជាដើម។ ច្បាប់នៅតែការពារទៅលើសិទ្ធិនិងករណីកិច្ចរបស់សន្តតិជនដែលនឹងត្រូវទទួលបាននូវចំណែកមត៌កទៅតាមលំដាប់និងចំណែកដែលសន្តតិជននីមួយៗមាន។

## ១.២. ការកើតឡើងនៃសន្តតិកម្ម

យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានកំណត់នៅ ក្នុងផ្នែកទី១ ជំពូកទី១ គន្ថីទី៨ ដែលបានចែងអំពី ការចាប់ផ្តើមសន្តតិកម្មដោយបានកំណត់យកពេលវេលានិងទីកន្លែងបើកសន្តតិកម្ម។ នៅក្នុងចំណុច នេះផងដែរ យើងខ្ញុំនឹងធ្វើការសិក្សាលំអិតទៅលើ ១.២.១. កាលបរិច្ឆេទចាប់ផ្តើមបើកសន្តតិកម្ម និង ១.២.២. ទីកន្លែងចាប់ ផ្តើមធ្វើសន្តតិកម្ម។

### ១.២.១.កាលបរិច្ឆេទចាប់ផ្តើមបើកសន្តតិកម្ម

ការចាប់ផ្តើមបើកសន្តតិកម្មដោយយោងតាមគោលការណ៍នៃច្បាប់ គឺលុះត្រាតែមតកជនទទួលមរណភាព ឬ ការបាត់ខ្លួនរបស់ មតកជន ទើបសន្តតិកម្មត្រូវ បានចាប់ផ្តើម។

[1] សន្ទានុក្រមនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

**ក. មរណភាពនៃបុគ្គល**

ជាការពិតណាស់ ការទទួលមរណភាពរបស់បុគ្គលម្នាក់ទាល់តែត្រូវបានវាយតម្លៃដោយអ្នកជំនាញ និង មានការត្រួតពិនិត្យ និង ការចេញលិខិតបញ្ជាក់អំពីការទទួលមរណភាពរបស់មន្ត្រីអត្រានុកូលដ្ឋាន។ ការស្លាប់គឺសន្មតថា មានសាកសពមួយ ព្រោះសាកសពជាភស្តុតាងបង្ហាញថាមានការស្លាប់។ ជាគោលការណ៍ច្បាប់បានកំណត់យកពេលទទួលមរណភាព គឺជាពេលវេលាមូលដ្ឋានក្នុងការចាប់ផ្តើមសន្តតិកម្ម។[2]

**ខ. ករណីបាត់ខ្លួន**

ការបាត់ខ្លួនក៏ជាលក្ខខណ្ឌមួយដែលគេសន្មត់បានថា បុគ្គលនោះបានទទួលមរណភាពផងដែរ។ នៅក្នុងករណីដែលគេមិនអាចរកភស្តុតាងដែលបញ្ជាក់បានថាបុគ្គលម្នាក់ស្លាប់ ដោយសារមិនអាចរកសាកសពឃើញ។ តាមលក្ខខណ្ឌគតិយុត្តត្រូវចាំបាច់មានសាលក្រមប្រកាសពីការបាត់ខ្លួន ព្រោះសាលក្រមមានអានុភាពអាចចាត់ទុកថាជនដែលបាន បាត់ខ្លួនស្លាប់បាត់ទៅហើយ។[3]

លក្ខខណ្ឌនៃការបាត់ខ្លួនបែងចែកជា ពីរករណីដូចខាងក្រោម៖

**ទី១:** ការបាត់ខ្លួនក្នុងលក្ខណៈធម្មតា គឺជាការបាត់ខ្លួនធម្មតាដែលត្រូវមានលក្ខខណ្ឌមិនដឹងថានៅរស់ ឬ ទទួលមរណៈភាពរយៈពេលយ៉ាងតិច ៥ ឆ្នាំហើយតុលាការត្រូវប្រកាសអំពីការបាត់ខ្លួននោះទៅតាមពាក្យសុំរបស់អ្នកដាក់ពាក្យសុំ។[4]

**ទី២:** ការបាត់ខ្លួនក្នុងលក្ខណៈពិសេស គឺជាការបាត់ខ្លួនក្នុងព្រឹត្តិការណ៍ពិសេស (គ្រោះថ្នាក់) ដូចជា សង្គ្រាម, ការលិចនាវា, ការរញ្ជួយផែនដី, អគ្គីភ័យ, ស៊ូណាមិ (រលកយក្ស) , ការរអិលផ្ទាំងទឹកកកពីភ្នំជាអាទិ៍ ដែលជាមូលហេតុនៃមរណភាពរបស់ជនដែលជួបប្រទះគ្រោះថ្នាក់ទាំងនេះហើយការមិនដឹងច្បាស់ថារស់ ឬ ទទួលមរណភាពនោះមានអំឡុងពេលយ៉ាងតិច ១ឆ្នាំគឺជាលក្ខខណ្ឌនៃការប្រកាសអំពីការបាត់ខ្លួន។[5] តុលាការត្រូវប្រកាសអំពីការបាត់ខ្លួនទៅតាមពាក្យសុំរបស់អ្នកដាក់ពាក្យសុំ។ កាលបរិច្ឆេទនៃការប្រកាសអំពីការបាត់ខ្លួនគឺជាពេលវេលានៃការបើកសន្តតិកម្មតាមច្បាប់។ ដោយសេចក្តីសម្រេចប្រកាសអំពីការបាត់ខ្លួនមានតម្លៃស្មើនឹងសំបុត្រមរណភាព។

**១.២.២.ទីកន្លែងចាប់ផ្តើមធ្វើសន្តតិកម្ម**

ការចាប់ផ្តើមសន្តិកម្មតាមច្បាប់ ត្រូវធ្វើឡើងនៅលំនៅឋានរបស់មតកជន។ ដោយច្បាប់បានកំណត់យកលំនៅឋាន គឺជាកន្លែងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ។[6] ក្នុងករណីមតកជនមិនមានលំនៅឋានពិតប្រាកដទេ ឬ មានលំនៅឋានច្រើនច្បាប់កំណត់យកទីសំណាក់ជាលំនៅឋាន។ ការកំណត់យកលំនៅឋានរបស់មតកជនជាទី

[2] មាត្រា១១៨៥ (១) នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[3] មាត្រា៤១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[4] មាត្រា៤១(១) នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[5] មាត្រា៤១(២) នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[6] មាត្រា១១៨៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

កន្លែងបើកសន្តតិកម្មគឺដោយសារភាពងាយស្រួល និង មានប្រសិទ្ធិភាពក្នុងការជូនដំណឹងជាសាធារណៈព្រោះលំនៅឋានមានផ្ទុកនូវព័ត៌មានពាក់ពន្ធ័នឹងមតកជនកាលនៅរស់ និង ងាយស្រួលក្នុងការកំណត់សមត្ថកិច្ចតុលាការក្នុងការចាប់ផ្ដើមសន្តតិកម្ម។

## ផ្នែកទី២ ៖លក្ខណៈសម្បត្តិជាសន្តតិជន

បន្ទាប់ពីបានសិក្សាស្វែងយល់ពីលក្ខខណ្ឌពាក់ព័ន្ធនឹងសន្តតិកម្ម និងសញ្ញាណទូទៅនៃសន្តតិកម្មហើយយើងនឹងសិក្សាអំពី ២.១.បុគ្គលដែលមានលក្ខណៈសម្បត្តិជាសន្តតិជន និង ២.២. បុគ្គលដែលមិនអាចទទួលសន្តតិកម្មបាន។

## ២.១.បុគ្គលដែលមានលក្ខណៈសម្បត្តិជាសន្តតិជន

### ២.១.១. រូបវ័ន្តបុគ្គល

លក្ខខណ្ឌចាំបាច់ដែលបានចែងក្នុងបញ្ញត្តិ **មាត្រា១១៤៩** នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧បានកំណត់ថាបុគ្គលដែលមានលក្ខណៈសម្បត្តិជាសន្តតិជន គឺជាបុគ្គលដែលមានជីវិតរស់រាននៅពេលចាប់ផ្ដើមបើកសន្តតិកម្ម មានន័យថាមានតែរូបវន្តបុគ្គលប៉ុណ្ណោះដែលអាចក្លាយជាសន្តតិជនបាន ព្រោះថារូបវន្តបុគ្គល គឺជាមនុស្សពិតតាមធម្មជាតិ ដែលមានសមត្ថភាពទទួលបានសិទ្ធិនៅពេលចាប់កំណើត ព្រមទាំងមានលក្ខណៈសម្បត្តិក្លាយជាប្រធាននៃសិទ្ធិនិងកាតព្វកិច្ចទៀតផង។ លើកទ្បែងតែបុគ្គលដែលច្បាប់បានបញ្ញត្តិថាជាអភ័ព្វបុគ្គល និង បុគ្គលដែលបានផ្ដាច់ចេញពីមត៌កប៉ុណ្ណោះដែលមិនអាចក្លាយជាសន្តតិជន និង មិនមានសិទ្ធិទទួលបានចំណែកមត៌ក។ បើសិនជាបុគ្គលដែលបានសន្មតថាជាសន្តតិជន ប៉ុន្តែបុគ្គលនោះបានទទួលមរណៈភាពមុនថ្ងៃបើកសន្តតិកម្មក៏ត្រូវបានចាត់ទុកថាមិនគ្រប់លក្ខណៈជាសន្តតិជនដែរ។ ក្នុងករណីមតកជន និងជនដែលសន្មតថា ជាសន្តតិជនបានទទួលមរណភាពព្រមគ្នា ឬ ត្រូវបានសន្មតថាទទួលមរណភាពព្រមគ្នាមិនត្រូវចាត់ទុកថាជននោះជាសន្តតិជនទេ ដោយសារតែមិនបានបំពេញលក្ខខណ្ឌរស់រានមានជីវិត នៅពេលចាប់ផ្ដើមសន្តតិកម្ម។[7]

### ២.១.២. ទារកក្នុងគភ៌

មួយវិញទៀតតើទារកដែលកំពង់នៅក្នុងគភ៌របស់ម្ដាយ ត្រូវបានចាត់ទុក ថាជាសន្តតិជនដែរឬទេ?

ចំពោះករណីទារកក្នុងគភ៌របស់ម្ដាយដោយយោងតាម**មាត្រា៩**កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានកំណត់ថាទារកដែលមាននៅក្នុងគភ៌ នាពេលចាប់ផ្ដើមសន្តតិកម្ម ត្រូវតែកើតមកមានជីវិតរស់រានទើបអាចបំពេញលក្ខខណ្ឌក្លាយជាសន្តតិជនបាន។ ប្រសិនបើទារកមានក្នុងគភ៌ម្ដាយនាពេលចាប់បើកសន្តតិកម្ម ប៉ុន្តែនៅពេលដែលកើតមកមិនមានជីវិតរស់រានទេ នោះមានន័យថាទារកនោះមិនអាចក្លាយជា

[7] មាត្រា៤៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

សន្តតិជនបានឡើយ ព្រោះថាទារកនោះមិនមែនជារូបវន្តបុគ្គល ដែលមានលក្ខណៈសម្បត្តិក្លាយជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ចទេ។

## ២.២.បុគ្គលដែលមិនអាចទទួលសន្តតិកម្មបាន

នៅក្នុងចំណុចនេះ យើងខ្ញុំនឹងធ្វើការសិក្សាទៅលើករណីចំនួន ២ ដែលបង្ហាញអំពីលក្ខខណ្ឌដែរនាំអោយសន្តតិជនបាត់បង់សិទ្ធិក្នុងការទទួលសន្តតិកម្មដែលករណីទី១ គឺជននោះក្លាយជាអភ័ព្វបុគ្គល និង ករណីទី២ ជននោះត្រូវបានផ្តាច់ចេញពីមតក៌ ។

### ២.២.១.ករណីអភ័ព្វបុគ្គល

យោងតាម **មាត្រា១១៥០** នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ "**អភ័ព្វបុគ្គល**" សំដៅទៅលើបុគ្គលទាំងឡាយណាដែលបាត់បង់សិទ្ធិជាសន្តតិជនដែលមិនអាចទទួលបានចំណែកមត៌ក ដោយសារតែបុគ្គលនោះស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- បុគ្គលដែលទទួលទោសដោយសារចេតនាធ្វើឃាត ឬប៉ុនប៉ងធ្វើឃាតលើមតកជន ឬលើជនដែលមានលំដាប់សន្តតិកម្មមុនឬលំដាប់ស្មើគ្នា ទោះដោយផ្ទាល់ក្តីឬដោយប្រយោលក្តី មានន័យថាបុគ្គលដែលបានរកឃើញថាមានចេតនាសម្លាប់មតកជន ដោយហេតុចង់បានទ្រព្យសម្បត្តិរបស់មតកជន ឬ ក៏មានចេតនាចង់សម្លាប់សន្តតិជនដែលមានលំដាប់ខ្ពស់ជាង ក្នុងចេតនាអោយខ្លួនមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការក្លាយទៅជាសន្តតិជនឬមានចេតនាសម្លាប់សន្តតិជនដែលមានលំដាប់ស្មើគ្នាក្នុងបំណងទទួលបានចំណែកមត៌ក។ ទោះបីជាក្នុងករណីបានធ្វើដោយប្រយោលក្តី ឬ ដោយផ្ទាល់ក្តី បុគ្គលនោះក៏ត្រូវចាត់ទុកជាអភ័ព្វបុគ្គល។
- បុគ្គលដែលដឹងពីការសម្លាប់មតកជនតែមិនបានរាយការណ៍ឬមិនបានប្តឹងត្រូវចាត់ទុកជាអភ័ព្វបុគ្គល។ ប៉ុន្តែប្រសិនបើ ជនដែលបានដឹងពីការសម្លាប់មតកជនតែមិនបានរាយការណ៍ គឺជាជនដែលមិនអាចធ្វើការវិនិច្ឆ័យដឹងខុសត្រូវ ឬ មានសតិមិនប្រក្រតីមិនអាចចាត់ទុកជននោះជាអភ័ព្វបុគ្គលបានទេ។
- បុគ្គលដែលបានធ្វើការរារាំងមតកជនក្នុងការលុបចោល ឬកែប្រែមតកសាសន៍ដែលស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែងត្រូវចាត់ទុកបុគ្គលនោះជាអភ័ព្វបុគ្គលដោយហេតុថាទង្វើរបស់បុគ្គលនោះជាអំពើមិនត្រឹមត្រូវដែល អាចធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍របស់សន្តតិជនដទៃទៀត។
- បុគ្គលដែលបានអោយមតកជនធ្វើការលុបចោល ឬ កែប្រែមតកសាសន៍ដោយឆបោក ឬ ដោយការគម្រាមកំហែងទង្វើនេះជាទង្វើមិនគប្បីដោយអោយមតកជនលុបចោល ឬ កែប្រែដោយផ្ទុយឆន្ទៈរបស់មតកជនដែលធ្វើអោយខូចប្រយោជន៍សន្តតិជនផ្សេងទៀត។
- បុគ្គលដែលបានក្លែងកែបន្លំខ្លឹមសារលិខិតមតកសាសន៍ អោយផ្ទុយពីខ្លឹមសារនៃលិខិតមតកសាសន៍ ដើម្បីបំផ្លាញចោល ឬ លាក់ទុកលិខិតមតកសាសន៍ក្នុងបំណងទទួលបានផលប្រយោជន៍ណាមួយ។

### ២.២.២. ការផ្តាច់មត៌កពីសន្តតិជន

មតកជនអាចដាក់ពាក្យសុំទៅកាន់តុលាការអោយផ្តាច់សន្តតិជនមិនអោយទទួលសន្តតិកម្ម ក្នុងករណីបើសន្តតិជននោះ បានប្រព្រឹត្តនូវសកម្មភាពដូចជាៈ

- បានធ្វើបាបចំពោះមតកជន
- បានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ
- អាចមកមើលថែទាំមតកជននៅពេលដែលមានជម្ងឺ តែមិនមកថែទាំ
- ត្រូវទទួលបានសាលក្រមឬសាលដីកាផ្តន្ទាទោសអោយជាប់ពន្ធនាគារមួយជីវិត
- បានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរអោយកត់សំគាល់ ជាអាទិ៍។[8]

## ២.៣. ករណីពិសេសចំពោះជនបរទេស

ជនដែលត្រូវបានចាត់ទុកគឺជាជនបរទេសជាជនណាដែលមិនមានសញ្ជាតិខ្មែរដោយគ្មានការរើសអើងអំពីសញ្ជាតិ ជំនឿ សាសនា ឬមានដើមកំណើតណាមួយក៏ដោយ។[9] សន្តតិជនដែលជាជនបរទេសក៏មានសិទ្ធិទទួលបានមត៌កពីមត៌កជនដែរ ប៉ុន្តែមិនអាចទទួលបានសន្តតិកម្មជាដីធ្លី ឬក៏អគារសហកម្មសិទ្ធិជាន់ក្រោមដី ឬជាន់ផ្ទាល់ដីទេ។ អគារសហកម្មសិទ្ធិជាអគារឬសំណង់ដែលមានម្ចាស់កម្មសិទ្ធិជាច្រើននាក់រស់នៅ មានចំណែកខ្លះជាកម្មសិទ្ធិផ្តាច់មុខរបស់សហកម្មសិទ្ធិករនីមួយៗដែលហៅថា ចំណែកឯកជន និងចំណែកខ្លះជាលំហរួមសម្រាប់ការប្រើប្រាស់រួមរបស់សហកម្មសិទ្ធិករទាំងអស់ដែលហៅថាចំណែករួម ដែលក្នុងចំណែករួមនោះមានដូចជា ដី ទីធ្លា ជណ្តើរ ដំបូល ឧទ្យាននិងសួនច្បារ ផ្លូវ ច្រកចេញចូល ជញ្ជាំងអឌ្ឍសិទ្ធិ ទីកន្លែងនៃសេវាកម្មរួម។[10] ជនបរទេសមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិចាប់ពីជាន់ទី១ឡើងទៅ។[11] យោងតាម **មាត្រា៨** នៃច្បាប់ភូមិបាលបានបញ្ញត្តិថា"មានតែរូបវន្តបុគ្គលឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេទើបមានសិទ្ធិជា ម្ចាស់កម្មសិទ្ធិលើដីនៃព្រះរាជាណាចក្រកម្ពុជា"។ ក្នុងករណីសន្តតិជនទាំងអស់មិនមានសញ្ជាតិខ្មែរនោះមត៌កដែលជា ដីធ្លីនឹងក្លាយជានីតិបុគ្គលមត៌កដោយស្វ័យប្រវត្តិ ហើយធ្វើការចាត់ចែងលើមត៌កនោះក្នុងនាមជានីតិបុគ្គលដែលជាម្ចាស់ សិទ្ធិចាត់ចែងមត៌ក។ សន្តតិជនទាំងអស់ត្រូវចាត់ចែងនីតិបុគ្គលមត៌កដោយដាក់លក់ដីធ្លី ដែលជាចំណែកមត៌កក្នុងអំឡុងពេល៣(បី)ខែគិតចាប់ពីថ្ងៃដែលសន្តតិជនទាំងអស់យល់ព្រមទាំងស្រុងឬយល់ព្រមមានកម្រិត រីឯថ្លៃដែលទទួលបានពីការលក់ដីធ្លីនោះ នឹងក្លាយជាមត៌ក ពេលនោះនីតិបុគ្គលមត៌កនឹងត្រូវរលត់។ ប្រសិនបើសន្តតិជនដែលមិនមានសញ្ជាតិខ្មែរ នោះមិនបានធ្វើការចាត់ចែងលើដីធ្លីនោះក្នុងរយៈពេលបីខែនោះទេ កម្មសិទ្ធិលើ

[8] មាត្រា១១៥១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[9] មាត្រា២ នៃច្បាប់ស្តីពីអន្តោប្រវេសន៍

[10] មាត្រា៤ នៃច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស

[11] មាត្រា៦ នៃច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស

ដីធ្លីនោះនឹងធ្វើសន្តតិកម្មដោយសន្តតិជនដែលមានលំដាប់បន្ទាប់ដែលមានសញ្ជាតិខ្មែរ។ បើសិនសន្តតិជនលំដាប់បន្ទាប់មិនមានសញ្ជាតិខ្មែរនោះទេ សន្តតិជននោះអចលនវត្ថុនោះនឹងត្រូវក្លាយជាកម្មសិទ្ធិរបស់រដ្ឋ។[12]

[12] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ទំព័រ១៣

# ជំពូកទី២
# បញ្ញត្តិនៃសន្តិកម្មតាមច្បាប់

# ជំពូកទី២៖ បញ្ញត្តិនៃសន្តតិកម្មតាមច្បាប់

## ផ្នែកទី១៖ សន្តិជនដែលច្បាប់បានកំណត់

ចំពោះការអនុវត្តសន្តតិកម្មតាមច្បាប់ គឺនៅពេលដែលមតកជនមិនបានបង្ហាញនូវឆន្ទៈរបស់ខ្លួន(បណ្តាំ) ក្នុងការបែងចែកចំណែកមត៌ករបស់ខ្លួននៅពេលដែលមតកជននោះមានជីវិត ដូចនេះហើយទើបបញ្ញត្តិនៃច្បាប់បានកំណត់ឱ្យមាន ការបែងចែកចំណែកមតក៌ទៅតាមលំដាប់នៃសន្តិតិជនដែលសន្តិតិជននីមួយៗទទួលបាននូវចំណែកមតក៌ទៅតាមលំដាប់ដែលខ្លួនត្រូវទទួលបាន។ ច្បាប់បានកំណត់នូវលំដាប់សន្តតិជនរបស់មតកជនដែលក្នុងនោះរួមមាន៖ សន្តតិជនលំដាប់ទី១ សន្តតិជនលំដាប់ទី២ និងសន្តតិជនលំដាប់ទី៣។ ក្រៅពីសន្តតិជនទាំងបីខាងលើនេះនៅមានសន្តតិជនដែលត្រូវទទួលបានមត៌កជានិច្ចហៅថា "សន្តតិជនជានិច្ច" និងសន្តតិជនដែលត្រូវទទួលបន្តហៅថា "សន្តតិជនជំនួស"។

## ១.១. លំដាប់នៃសន្តតិជន

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានបែងចែកលំដាប់នៃសន្តិជនជា៣ដែលអ្នកដែលមានសិទ្ធិនោះ គឺជាញាតិលោហិតរបស់មតកជន។

### ១.១.១. សន្តតិជនលំដាប់ទី១

ដោយយោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ សន្តតិជនលំដាប់ទី១គឺសំដៅទៅលើបុគ្គលដែលមានអត្តិភាពមុនគេក្នុងការទទួលបាននូវចំណែកមត៌ករបស់មតកជន។ **មាត្រា១១៥៦** នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បានចែងថា "កូនរបស់មតកជនត្រូវក្លាយជាសន្តតិជនដែលមានលំដាប់ទី១"។ កថាខណ្ឌទី២នៃមាត្រាដដែលនេះបានបង្ហាញថាកូនបង្កើតឬកូនសុំត្រូវមានចំណែកមត៌កស្មើៗគ្នា។ ក្នុងន័យនេះកូនរបស់មតកជន គឺចង់សំដៅទៅលើកូនដែលមានបុត្តភាពត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់[13] ដោយ រាប់ទាំងកូនដែលកើតក្រៅចំណងអាពាហ៍ពិពាហ៍(កូនឥតខាន់ស្លា), កូនបង្កើតដែលមានចំណងអាពាហ៍ពិពាហ៍ និង កូនសុំរបស់មតកជនក្នុងករណីដែលមតកជនពេលនៅរស់បានបង្កើតសុំកូនស្របច្បាប់ហើយកូនសុំនោះត្រូវ បានច្បាប់ទទួលស្គាល់ នោះកូននីមួយៗត្រូវបានចាត់ទុកជាសន្តតិជនមានលំដាប់ទី១ និង ទទួលបានចំណែក មត៌កស្មើៗគ្នា។

ចំពោះកូនក្រៅអាពាហ៍ពិពាហ៍ទៀតសោតទោះបីជាមានទំនាក់ទំនងបិតុភាពបង្កើតក៏ដោយប្រសិនបើជាទំនាក់ទំនងនោះមិនត្រូវបានទទួលស្គាល់តាមច្បាប់នោះទេបុត្តភាពតាមផ្លូវច្បាប់ក៏មិនអាចទទួលស្គាល់បានដែរ ដូច្នេះកូនដែលមិនត្រូវបានទទួលស្គាល់នោះមិនអាចទទួលបាននូវចំណែកមត៌ក និង ក្លាយជាសន្តតិជនរបស់ឪពុកបានឡើយ។ ជាទូទៅសំបុត្រកំណើតគឺជាភស្តុតាងមួយដ៏សំខាន់ក្នុងការបញ្ជាក់ពីទំនាក់ទំនងគតិយុត្តរវាងកូន និង

[13] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ទំព័រ១៤

ឪពុកម្តាយ[14]។ វាជាករណីយកិច្ចរបស់ឪពុកម្តាយដែលត្រូវសុំចុះសំបុត្រកំណើតកូន ទោះបីជាឪពុកម្តាយនោះបានរៀបអាពាហ៍ពិពាហ៍ឬមិនបានរៀបអាពាហ៍ពិពាហ៍ក៏ដោយ។ ការចុះអត្រានុកូលដ្ឋានគឺជាតួនាទីរបស់មន្ត្រីអត្រានុកូលដ្ឋានដែលជាមេឃុំឬចៅសង្កាត់ស្ថិតក្នុងដែនដីឃុំឬសង្កាត់ដែលខ្លួនបានគ្រប់គ្រង។[15]

ចំពោះកូនសុំនៃការសុំកូនពេញលេញញាតិភាពតាមផ្លូវច្បាប់ជាមួយនឹងឪពុកម្តាយបង្កើតត្រូវបានបញ្ចប់[16] ដូចនេះកូនសុំពេញលេញមិនអាចក្លាយជាសន្តតិជនរបស់ឪពុកម្តាយបង្កើតទេ ពោលគឺអាចក្លាយជាសន្តតិជនចំពោះតែឪពុកម្តាយចិញ្ចឹមប៉ុណ្ណោះ។ រីឯកូនសុំនៃការសុំកូនធម្មតាវិញអាចទទួលសន្តតិកម្មពីឪពុកម្តាយបង្កើតផង និងពីឪពុកម្តាយចិញ្ចឹមផង។[17]

### ១.១.២. សន្តតិជនលំដាប់ទី២

សន្តតិជនលំដាប់ទី២ កើតឡើងនៅពេលដែលមតកជនមិនមានសន្តតិជនណាដែលស្ថិតនៅលំដាប់ទី១ ពោលគឺ មតកជនមិនមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជននោះឡើយដូចនេះសិទ្ធិ និង កាតព្វកិច្ចរបស់មតកជនដែលបានបន្សល់ទុកគឺត្រូវបានបែងចែកទៅឱ្យសន្តតិជនដែលមានលំដាប់ទី២ ដែលសន្តតិជនលំដាប់ទី២ គឺជាបុព្វញាតិខ្សែផ្ទាល់ថ្នាក់ទី១របស់មតកជនរួមមានឪពុកម្តាយ ឬជីដូនជីតារបស់មតកជន។[18] មូលហេតុដែលគេបានកំណត់យកបុព្វញាតិផ្ទាល់ដែលជាឪពុកម្តាយ ឬ ជីដូនជីតារបស់មតកជនជាសន្តតិជនលំដាប់ទី២ដោយគេយល់ឃើញថាអ្នកទាំងនោះគឺជាអ្នកដែលបានមើលថែទាំ ចិញ្ចឹមបីបាច់ មតកជន ដែលជាកូន ឬចៅ។ អ្នកដែលជាបុព្វញាតិដែលមានថ្នាក់ញាតិខុសគ្នា គេកំណត់យកអ្នកដែលមានលំដាប់ថ្នាក់ញាតិជិតជាងគេទៅនឹងមតកជនជាអ្នកដែលមានអាទិភាពទទួលបានចំណែកមតិក។ នៅក្នុងករណីដែលមតកជនមានទាំងឪពុកម្តាយនិងជីដូនជីតានោះ ឪពុកម្តាយរបស់មតកជននឹងក្លាយជាសន្តតិជនលំដាប់ទី២មុនជីដូនជីតាដោយហេតុថាឪពុកម្តាយមានថ្នាក់ញាតិជិតទៅនឹងមតកជនជាងជីដូនជីតា។ ប៉ុន្តែក្នុងករណីដែលមតកជនមិនមានឪពុកម្តាយគឺជីដូនជីតានឹងក្លាយជាសន្តតិជនលំដាប់ទី២ ដែលជីដូនជីតាអាចមានទាំង ខាងម្តាយ និង ខាងឪពុក ដូចនេះជីដូនជីតាទាំងសងខាងគឺជាសហសន្តតិជន។ នៅពេលដែលបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនមានចំនួនច្រើននាក់នោះបុព្វញាតិផ្ទាល់នីមួយៗត្រូវទទួលបានចំណែកមត៌កស្មើៗគ្នា។

---

[14] មាត្រា១៩ អនុក្រឹត្យ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន

[15] មាត្រា១៣ នៃច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាននិងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣

[16] មាត្រា១០១៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[17] មាត្រា១០២៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[18] មាត្រា១១៥៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

### ១.១.៣. សន្តតិជនលំដាប់ទី៣

នៅក្នុងករណីដែលមតកជនមិនមានទាំងបច្ឆាញាតិនិងបុព្វញាតិដែលនឹងត្រូវក្លាយជាសន្តតិជនទេ នោះវត្តមាននៃសន្តតិជនលំដាប់ទី៣នឹងកើតមានឡើងដែរសន្តតិជនលំដាប់ទី៣គឺជាបងប្អូនបង្កើតរបស់មតកជន។[19] ប្រសិនបើមតកជនមានបងប្អូនបង្កើតច្រើននាក់នោះបងប្អូនបង្កើតម្នាក់ៗត្រូវទទួលបានចំណែកមត៌កស្មើៗគ្នា។ យ៉ាងណាមិញចំពោះបងប្អូនបង្កើតដែលមានឪពុកឬម្តាយតែម្ខាង ត្រូវទទួលបានចំណែក១/២(មួយភាគពីរ) នៃចំណែកមត៌ករបស់បងប្អូនដែលមានឪពុកនិងម្តាយរួមទាំងសងខាង។[20]

## ១.២. សន្តតិជនជានិច្ច

បើកាលនៅរស់មតកជនមានសហព័ទ្ធស្របច្បាប់ នោះសហព័ទ្ធរបស់មតកជនទោះមិនមែនជាញាតិលោហិតផ្ទាល់ក្តីក៏មានសិទ្ធិក្នុងការទទួលបានចំណែកមត៌ករបស់មតកជនដែរ។ ដោយហេតុថាជាគោលការណ៍ក្រោយរៀបអាពាហ៍ពិពាហ៍សហព័ទ្ធទាំងពីរមានសិទ្ធិ និង កាតព្វកិច្ចរួមរស់ជាមួយគ្នា និង រួមទាំងការបង្កើតបង្កើនទ្រព្យសម្បត្តិផងដែរ ដូចនេះ សហព័ទ្ធបានទទួលឋានៈជាសន្តតិជនជានិច្ច។[21] ទោះបីជាមាននូវសន្តតិជនឬគ្មានសន្តតិជនផ្សេងៗទៀតក៏ដោយក៏សហព័ទ្ធត្រូវបានច្បាប់ទទួលស្គាល់សិទ្ធិសន្តតិកម្ម ហើយជាពិសេសត្រូវទទួលបាននូវមត៌កដែលជាចំណែកនៃទ្រព្យដោយឡែកនិងទ្រព្យរួមរបស់មតកជន។ ពាក្យថា "**ជានិច្ច**" នៅក្នុងន័យនេះសំដៅទៅលើ ការគ្មានការពាក់ព័ន្ធនឹងអត្ថិភាពរបស់សន្តតិជនផ្សេងទៀតព្រមទាំងលំដាប់នៃសន្តតិកម្មឡើយ។ សន្តតិជនជានិច្ចត្រូវទទួលបាននូវចំណែកមត៌កជាមួយនឹងសន្តតិជនផ្សេងៗទៀតគ្រប់លំដាប់ទាំងអស់ ដោយមិនគិតថា ជាបុព្វញាតិបច្ឆាញាតិឬក៏ជាបងប្អូនបង្កើតឡើយ។ ការបែងចែកចំណែកមត៌កនៅក្នុងករណីដែលមតកជនមានទាំងញាតិលោហិតដែលត្រូវក្លាយជាសន្តតិជននិងមានសហព័ទ្ធមានចែងនៅក្នុង **មាត្រា១១៦២**នៃក្រមរដ្ឋប្បវេណី៖

- បើសហព័ទ្ធ និង បច្ឆាញាតិផ្ទាល់របស់មតកជនជាសន្តតិជននោះសហព័ទ្ធ និង កូននីមួយៗនឹត្រូវទទួលចំណែកមត៌កស្មើគ្នា។
- បើសហព័ទ្ធ និង ឪពុកម្តាយរបស់មតកជនជាសន្តតិជននោះ ចំណែកមត៌ករបស់សហព័ទ្ធត្រូវជា១/៣ (មួយភាគបី)ឯចំណែកមត៌កឪពុកម្តាយត្រូវជា២/៣ (ពីរភាគបី)។ ប៉ុន្តែបើឪពុកឬម្តាយរបស់មតកជនតែម្នាក់នៅរស់ឪពុកម្តាយនោះ និង សហព័ទ្ធត្រូវបានចំណែកមត៌កស្មើគ្នា។
- បើសហព័ន្ធ និង បុព្វញាតិផ្ទាល់ក្រៅពីឪពុកម្តាយរបស់មតកជន ឬបងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសបុគ្គលទាំងនោះជាសន្តតិជនចំណែកមត៌ករបស់សហព័ទ្ធត្រូវជា១/២ (មួយភាគ

[19] មាត្រា១១៦០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[20] មាត្រា១១៦០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧+

[21] មាត្រា១១៦១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ពីរ) ឯចំណែកមត៌ករបស់បុព្វញាតិផ្ទាល់ក្រៅពីឪពុកម្តាយរបស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសនោះត្រូវជា ១/២ (មួយភាគពីរ)។

ប្រសិនបើមតកជនគ្មានសន្តតិជនពីលំដាប់ទី១ដល់លំដាប់ទី៣នោះទេ សហព័ទ្ធនឹងទទួលសន្តតិកម្មតែម្នាក់ឯង។ ប៉ុន្តែក្នុងករណីដែលសហព័ទ្ធនោះជាអភ័ព្វបុគ្គល ឬជាបុគ្គលដែលត្រូវផ្តាច់ពីសន្តតិកម្មសហព័ទ្ធនោះមិនអាចទទួលសន្តតិកម្មបានឡើយទោះបីជាសហព័ទ្ធរបស់មតកជនក៏ដោយ។

## ១.៣. សន្តតិជនជំនួស

សន្តតិជនជំនួសអាចកើតមានឡើងក្នុង ២ករណីទី១គឺ សន្តតិជនជាអភ័ព្វបុគ្គល ឬ ជនដែលផ្តាច់ពីមត៌ក និង ទី២សន្តតិជនបានទទួលមរណភាព។ ក្នុងករណីទី១ដែលសន្តតិជនជាអភ័ព្វបុគ្គល ឬជនដែលបានផ្តាច់ចេញពីចំណែកមត៌កក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បានបង្កើតឱ្យមាននូវសន្តតិជនជំនួស ដើម្បីទទួលបាននូវចំណែកមត៌កជំនួសពីជនដែលជាអភ័ព្វបុគ្គល ឬជនដែលបានផ្តាច់ចេញពីចំណែកមត៌ក។ សន្តតិជនជំនួសគឺជាបច្ឆាញាតិនៃជននោះពោលគឺសន្តតិជនជំនួសអាចជាកូន ឬចៅនៃអភ័ព្វបុគ្គល ឬ ជនដែលត្រូវបានផ្តាច់ពីមត៌ក។

ក្នុងករណីទី២ ប្រសិនបើកូនរបស់មតកជនទទួលមរណភាពនៅមុន ឬ ស្របពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិក្លាយជាសន្តតិជន នោះកូនរបស់បុគ្គលនោះត្រូវក្លាយជាសន្តតិជនជំនួសដែលជននោះត្រូវតែជាបច្ឆាញាតិផ្ទាល់របស់មតកជន។ ចំពោះករណីដែលកូនរបស់មតកជនទទួលមរណភាពក្រោយពេលចាប់ផ្តើមសន្តតិកម្ម សន្តតិជនដែលស្លាប់នោះទទួលសន្តតិកម្មរបស់មតកជន ហើយកូនរបស់សន្តតិជនដែលស្លាប់នោះនឹងទទួលសន្តតិកម្មបន្តទៀត ដោយសារតែមរណភាពរបស់សន្តតិជនដែលស្លាប់នោះ។

ចំពោះករណីសុំកូនវិញនៅពេលដែលជនបានសុំកូនដែលមានកូនរួចហើយតាមរយៈសុំកូនធម្មតា នោះកូនរបស់កូនសុំនោះមិនអាចក្លាយជាសន្តតិជនជំនួសបានឡើយ ដោយសារកូននោះមិនមែនជាបច្ឆាញាតិផ្ទាល់របស់មតកជន។ ប៉ុន្តែលើកលែងក្នុងករណីដែលកូនរបស់កូនសុំធម្មតានោះកើតក្រោយពេលដែលបានសុំកូន កូននោះអាចក្លាយជាសន្តតិជនជំនួសបាន ដោយហេតុថាកូនដែលកើតនោះជាបច្ឆាញាតិផ្ទាល់របស់មតកជននិងមិនអាចត្រូវបានហាមឃាត់ដោយវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ នៃមាត្រា ១១៥៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ទេ។

# ផ្នែកទី២៖ ការបែងចែកមត៌កទៅតាម ចំណែករបស់សន្តតិជន

ទោះជានៅក្នុងបញ្ញត្តិនៃច្បាប់បានចែងអំពីលំដាប់នៃសន្តតិជនហើយ ក៏ប៉ុន្តែការប៉ានស្មានទៅលើចំណែកដែលសន្តតិជនត្រូវទទួលបាន និងការបែងចែកចំណែកសន្តតិកម្មអាចមានភាពស្រពិចស្រពិលនៅក្នុងករណីដែល

សហសន្តិជនមានច្រើននាក់។ នៅក្នុងផ្នែកនេះ យើងខ្ញុំសូមលើកនូវរូបមន្តនៃការបែងចែកមរតកទៅតាមចំណែកនៃសន្តតិកម្មដែលសន្តតិជនត្រូវទទួលបាន។

## ២.១. ករណីសន្តតិជនមានតែបច្ឆាញាតិ

ដូចដែលមានចែងនៅក្នុង **មាត្រា១១៥៦** នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បច្ឆាញាតិផ្ទាល់(កូន)គឺមានលំដាប់ទី១ក្នុងការក្លាយជាសន្តតិជនរបស់មតកជន។ ក្នុងករណីនេះគឺយើងសម្តៅដល់បច្ឆាញាតិដែលជាកូនរបស់មតកជនថាត្រូវទទួលបានចំណែកមត៌កបានប៉ុន្មាន។ "កូនរបស់សន្តតិជនដែលជាកូនបង្កើតក្តី ឬ កូនសុំក្តីត្រូវទទួលបានចំណែកមត៌កពីមតកជនស្មើៗគ្នា"[22]។ នៅពេលដែលសន្តតិជនមានច្រើននាក់ចំណែកមត៌ករបស់មតកជនត្រូវចែកឱ្យបានស្មើៗគ្នាទៅដល់សន្តតិជននីមួយៗ តែប្រសិនបើសន្តតិជនមានតែម្នាក់នោះមិនចាំបាច់បែងចែកឡើយ។

**ឧទាហរណ៍៖** ពូសុខ មានកូនបង្កើតចំនួន២នាក់ A និងB។ បន្ទាប់មកពូសុខបានទៅសុំកូនពេញលេញ C ចំនួន១នាក់បន្ថែមទៀត។ ក្រោយមកទៀត ពូសុខ ក៏បានទទួលមរណភាពបន្សល់ទុកនូវទ្រព្យសម្បត្តិគិតជាប្រាក់សរុបចំនួន 60000$។ តើអ្នកណាអាចក្លាយជាសន្តតិជនរបស់ពូសុខ ហើយត្រូវទទួលបានចំណែកមត៌កចំនួនប៉ុន្មាន?

នៅក្នុងករណីខាងលើ យោងតាមមាត្រា១១៥៦ កូនត្រូវក្លាយជាសន្តតិជនលំដាប់ទី១ ហើយកូននីមួយៗ ទោះបីជាកូនបង្កើតក្តី ឬកូនសុំក្តី ត្រូវទទួលបានចំណែកមត៌កស្មើៗគ្នា។ ដោយពូសុខ មានកូន៣ នាក់ A B និង C, ដូចនេះ A B និង C ត្រូវក្លាយជា សន្តតិជនរបស់ពូសុខ។ A B និង C ត្រូវទទួលបានចំណែកសន្តតិជនស្មើៗគ្នា គឺមួយនាក់ទទួលបានចំណែក ១/៣ (មួយភាគបី) នៃមត៌កសរុប។

| |
|---|
| **រូបមន្តរកចំណែកមត៌ករបស់សន្តតិជននីមួយៗ= មត៌កសរុប ÷ ចំនួនសន្តតិជនសរុប** |

➔ចំណែកមត៌ករបស់សន្តតិជននីមួយៗគឺ **60000 ÷ 3 = 20000**

ដូចនេះ **A B** និង **C** ទទួលមានចំណែកមត៌ក ម្នាក់**20000$**។

ក្នុងករណីដែល សន្តតិជនបាន ទទួលមរណភាពមុនពេលបើកសន្តតិកម្ម ឬបាត់បង់សិទ្ធិដោយបុព្វហេតុណាមួយផ្សេងៗ(អភ័ព្វបុគ្គលជាអាទិ៍) នោះចំណែកមត៌ករបស់ជននោះនឹងបានទៅលើកូនរបស់សន្តតិជនវិញ។

**ឧទាហរណ៍ទី២៖** ពូសៅ មានកូនចំនួន៣នាក់គឺ ក ខ និងគ។ នៅមុនពេលដែលបើកសន្តតិកម្ម ក បានទទួលមរណភាពដោយសារជម្ងឺ ហើយគាត់មានកូនចំនួន២នាក់ គឺ ក១ និង ក២។ ចំណែក គ វិញជាអភ័ព្វបុគ្គល តែគាត់មានកូនចំនួន៣នាក់ គឺ គ១ គ២ និង គ៣។ ក្រោយមកទៀត ពូសៅក៏បានស្លាប់បន្សល់ទុកនូវទ្រព្យសម្បត្តិ

[22] មាត្រា១១៥៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

គិតជាប្រាក់សរុបចំនួន 6000$។ តើអ្នកណាអាចក្លាយជាសន្តតិជនរបស់ពូសៅ ហើយត្រូវទទួលបានចំណែកមត៌កចំនួនប៉ុន្មាន?

នៅក្នុងករណីខាងលើនេះដោយយោងតាមមាត្រា១១៥៦ កូនរបស់ពូសៅ ក ខ និងគ ត្រូវក្លាយជាសន្តតិជនទទួលបានចំណែកមត៌ក ម្នាក់ ១/៣ (មួយភាគបី) នៃមត៌កសរុប។

ចំណែកមត៌ករបស់សន្តតិជននីមួយៗគឺ 6000 ÷ 3 = 2000

តែ ក បានស្លាប់ ហើយ គ បានក្លាយជាអភ័ព្វបុគ្គល នោះ ក និង គ មិនអាចទទួលចំណែកមត៌កបានទេ។ ប៉ុន្តែដោយយោងតាមមាត្រា ១១៥៧ និង ១១៥៨ កូន របស់ ក និង គ អាចក្លាយជាសន្តតិជនជំនួស ទទួលនូវចំណែកមត៌ក របស់ ក និង គ។ ដោយ ក មានកូន២នាក់ ក១ និង ក២ ដូចនេះ ក១ និងក២ ត្រូវទទួលបានចំណែកមត៌ករបស់កូនក្នុងចំណែកស្មើៗគ្នា

➔ ក១= ក២= 2000 ÷ 2 = 1000

ដោយ គ មានកូន៣នាក់ គ១ គ២ និង គ៣ ដូចនេះ គ១ គ២ និង គ៣ ត្រូវទទួលបានចំណែលមត៌ករបស់ គ ក្នុងចំណែកស្មើៗគ្នា

➔ គ១= គ២= គ៣= 2000 ÷ 3 = 666.666$

## ២.២. ករណីសន្តតិជនមានតែបុព្វញាតិ

នៅក្នុងករណីនេះ យើងសិក្សាពីទៅលើការបែងចែកចំណែកដែលសន្តតិជនមាន តែបុព្វញាតិ(ឪពុកម្តាយ ឬជីដូនជីតា)។ ដូចដែលយើងខ្ញុំបានបកស្រាយពីខាងលើរួចមកហើយថាអ្នកដែលជាបុព្វញាតិ ដែលមានលំដាប់ថ្នាក់ញាតិជិតជាងគេទៅនឹងមតកជនជាអ្នកដែលមានអាទិភាពទទួលចំណែកមត៌ក មានន័យថាឪពុកម្តាយ ជាអ្នកទទួលបានមត៌កមុនជីដូនជីតា ប៉ុន្តែក្នុងករណីដែលគ្មានឪពុកម្តាយទេនោះ ជីដូនជីតានឹងត្រូវក្លាយជាសន្តតិជនបន្តដោយត្រូវទទួលបានចំណែកមត៌កស្មើៗគ្នា។ ការដែលសន្តតិកម្មត្រូវបានទៅលើសន្តតិជនលំដាប់ទី២ គឺនៅករណីដែលមតកជននោះមិនមានកូនក្នុងការស្នងមត៌ករបស់ខ្លួននោះទេ ហេតុនេះហើយឪពុកម្តាយ ឬជីដូនជីតា របស់មតកជន ដែលជាបុព្វញាតិនឹងត្រូវក្លាយជាសន្តតិជន។[23] នៅក្នុងករណីដែលមានឪពុកម្តាយច្រើននាក់(តាមរយៈសុំកូនធម្មតា)នោះចំណែកនៃសន្តតិជននីមួយៗត្រូវទទួលបានស្មើៗគ្នា។

**ឧទាហរណ៍៖ ករណីទី១**: មីនា រស់នៅជាមួយ ឪពុក(ក) ម្តាយ (ខ) និង ជីដូន (គ) ក្នុងផ្ទះតែមួយ។ ថ្ងៃមួយ មីនា ជិះម៉ូតូទៅធ្វើការ រួចក៏បានជួបប្រទះគ្រោះថ្នាក់ចរាចរណ៍ ហើយក៏បានបាត់បង់ជីវិត។ មីនា បានបន្សល់ទុកនូវទ្រព្យសម្បត្តិគិតជាប្រាក់ស្មើ 10000$។ តើអ្នកណាអាចក្លាយជាសន្តតិជនរបស់មីនា ហើយត្រូវទទួលបានចំណែកមត៌កចំនួនប៉ុន្មាន?

[23] មាត្រា១១៥៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

នៅក្នុងករណីខាងលើ ដោយយោងតាមមាត្រា ១១៥៩ បើមតកជនមិនមានកូននោះទេ នោះបុព្វញាតិផ្ទាល់នឹងត្រូវក្លាយជាសន្តតិជន បុព្វញាតិដែលមានថ្នាក់ញាតិជិតជាងគេគឺមានអទិភាពមុនគេ។ នៅក្នុងករណីទី១ ខាងលើ យើងឃើញថាមីនា មានបុព្វញាតិផ្ទាល់ ជាឪពុក(ក)ម្តាយ(ខ)ផង និងជីដូន(គ)ផង តែដោយឪពុកម្តាយមានថ្នាក់ញាតិជិតជាងជីដូន ដូចនេះ ឪពុក(ក) និងម្តាយ(ខ) ត្រូវក្លាយជាសន្តតិជនរបស់មីនា ទទួលបានចំណែកមត៌កស្មើៗគ្នា។

➔ ក=ខ= 10000 ÷2 = 5000$

**ករណីទី២:** ឪពុកម្តាយមីនា បានស្លាប់តាំងពីមីនានៅក្មេង ហើយមីនារស់នៅតែជាមួយជីដូន(គ) នោះទេ។

នៅក្នុងករណីខាងលើ ដោយ មីនាមិនមានកូន ហើយក៏មិនមានឪពុកម្តាយទៀត នោះជីដូន(គ) របស់មីនាគឺជាបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនរបស់មីនា ទទួលបានចំណែកមត៌ករបស់មីនា។

**ករណីទី៣:** ឪពុក(ក) និង ម្តាយ(ខ)បានសុំមីនា ពីពូសេន និង មីងសំ នៅពេលមីនាអាយុ១០ឆ្នាំ(សុំកូនធម្មតា)។ តើអ្នកណាអាចក្លាយជាសន្តតិជនរបស់មីនា ហើយត្រូវទទួលបានចំណែកមត៌កចំនួនប៉ុន្មាន?

នៅក្នុងករណីខាងលើ យោងមាត្រា ១១៥៩ បានកំណត់ថាបើមតកជនមិនមានបច្ឆាញាតិផ្ទាល់ទេ បុព្វញាតិផ្ទាល់របស់មតកជននឹងក្លាយជាសន្តតិជន។ ចំណែកឯមាត្រា១០២៦បានចែងថាញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើតមានអត្ថិភាព និងមានសិទ្ធិធ្វើសន្តតិកម្មទៅវិញទៅមក។

ហេតុនេះ ឪពុក(ក) ម្តាយ(ខ) ពូសេន និងមីងសំ គឺត្រូវក្លាយជាសហសន្តតិជនរបស់មីនា ដែលទទួលបានចំណែកមត៌កស្មើៗគ្នា

➔ក=ខ=ពូសេន=មីងសំ= 10000 ÷ 4 = 2500$

## ២.៣. ករណីសន្តតិជនមានតែបងប្អូនបង្កើត

នៅពេលដែលមកតជនមិនមានទាំងបុព្វញាតិនិងបច្ឆាញាតិក្នុងការទទួលសន្តតិកម្មទេ នោះបងប្អូនបង្កើតរបស់មតកជនត្រូវក្លាយជាសន្តតិជន។ បងប្អូនបង្កើតរួមមានបងប្អូនបង្កើតដែលមានឪពុកម្តាយរួមនោះបងប្អូននីមួយៗ ត្រូវទទួលបានចំណែកស្មើៗគ្នា។ ប៉ុន្តែបើបងប្អូនបង្កើតដែលមានឪពុកតែម្ខាង ឬម្តាយតែម្ខាងរួមគ្នាត្រូវទទួលបានចំណែក១/២ (មួយភាគពីរ) នៃចំណែករបស់បងប្អូនបង្កើតដែលមានទាំងឪពុកនិងម្តាយរួមគ្នា។

**ឧទាហរណ៍៖** ពូកុសល មានទំនាក់ទំនងជាមួយនឹងមីងកញ្ញា រួចក៏មានកូន២នាក់ A និង B តែពូកុសលបានបែកគ្នាជាមួយមីងកញ្ញា ហើយក៏បានទៅរៀបការជាមួយមីងសំ។ ក្រោយមក ពូកុសល និងមីងសំ ក៏មានកូនជាមួយគ្នាចំនួន៣នាក់ ក ខ និង គ។ លុះក្រោយ មកទៀត ក ក៏បានទទួលមរណភាពដោយសារជម្ងឺមហារីក ហើយបានបន្សល់ទុកនូវទ្រព្យសម្បត្តិ គិតជាប្រាក់សរុបស្មើ 25000$។ (សន្មតថា ក មិនមានកូននោះឡើយ ហើយពូ

កុសលនិងមីងសំបានស្លាប់ហើយ) តើអ្នកណាអាចក្លាយជាសន្តតិជនរបស់"ក"ហើយមានចំណែកមត៌កចំនួនប៉ុន្មាន?

នៅក្នុងករណីខាងលើ៖ យោងមាត្រា១១៦០ បានកំណត់ថា បើមតកជនមិនមាន បច្ឆាញាតិផ្ទាល់ បុព្វញាតិផ្ទាល់ ដូចនេះ បងប្អូនបង្កើតរបស់មតកជនអាចក្លាយជាសន្តតិជន។ ចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុកឬម្តាយតែម្ខាងដូចគ្នា ត្រូវមាន ១ ភាគ ២ (មួយភាគពីរ) នៃចំណែកមត៌ករបស់បងប្អូនដែលមានឪពុកនិងម្តាយទាំងសងខាងដូចគ្នា។

ដោយ"ក" មិនមានកូន និងឪពុកម្តាយនៅរស់ទេ នាំឱ្យបងប្អូនរបស់"ក" ត្រូវក្លាយជាសន្តតិជនរបស់"ក" រួមមានទាំង ខ គ A និងB។

**-គណនាចំណែកមត៌ក បងប្អូននីមួយៗទទួលបាន**

ដោយ ខ និង ក មានទាំងម្តាយនិងឪពុករួមជាមួយនឹង"ក" នាំឱ្យ ខ និង គទទួលបានចំណែកស្មើៗគ្នា។

រីឯ AនិងB មានតែឪពុករួមជាមួយនឹង"ក" នាំឱ្យ AនិងB ទទួលបានចំណែកពាក់កណ្តាល នៃ ចំណែកដែល ខ និង គ ទទួលបាន។

តាងx ជាចំណែកដែល ខ និង គ ទទួលបាន

នាំឱ្យ ចំណែករបស់ AនិងB = x/2

➔ចំណែកមត៌កសរុប= x+x+x/2+x/2 = 1

3x=1 => x= 1/3

ដូចនេះចំណែករបស់ ខ និង គ គឺ ១/៣

⇨ 1/3 x 25000= 8333.33 ➔ ខ=គ=8333.33$

រីឯចំណែករបស់ AនិងB គឺ ១/៣÷២=១/៦

⇨ 1/6 x 25000= 4166.66 ➔ A=B=4166.66$

នៅក្នុងករណីដែលសន្តតិជនដែលជាបងប្អូនបង្កើតរបស់មតកជនទទួលមរណភាព ឬផ្តោះសិទ្ធជាសន្តតិជន ដោយមូលហេតុណាមួយ នោះសន្តតិកម្មជំនួសនឹងត្រូវយកមកអនុវត្ត ដោយកូនរបស់សន្តតិជន (ជាក្មួយប្រុសឬក្មួយស្រីរបស់មតកជន)នឹងក្លាយជាសន្តតិជនជំនួស។ ឧទាហរណ៍ក្នុងករណីខាងលើ មតកជន "ក" មានបងប្អូនបង្កើតចំនួន២នាក់គឺ ខ និង គ រួមទាំងបងប្អូនរួមឪពុក២នាក់គឺ A និង B។ ខ បានស្លាប់ហើយ មានកូនចំនួន២នាក់គឺ ខ១ និង ខ២ ឯអភ័ព្វបុគ្គល A មានកូនចំនួន ៣នាក់គឺ A១ A២ និងA៣។ យើងអាចគណនាបានថា៖

គ ទទួលបាន ១/៣ (មួយភាគបី)

ខ១ និងខ២ ជាសន្តតិជនជំនួសរបស់ ខ ត្រូវទទួលបានចំណែកស្មើគ្នានៃចំណែករបស់ខ គឺយក ១/៣ ចែកនឹង២ នាំឱ្យ ខ១និងខ២ ទទួលបានចំណែក ១/៦ (មួយភាគប្រាំមួយ)

B ទទួលបាន ១/៦(មួយភាគប្រាំមួយ)

A១និងA២ ជាសន្តតិជនជំនួសរបស់ A ទទួលបានចំណែកស្មើគ្នានៃចំណែករបស់A ដោយយក១/៦ ចែកជា២ នាំឱ្យ A១និងA២ ទទួលបាន១/១២ (មួយភាគដប់ពីរ)

## ២.៤. ករណីដែលសន្តតិជនមានសហព័ទ្ធ រួមជាមួយនឹងញាតិ

ក្រមរដ្ឋប្បវេណីនៃព្រះរាជណាចក្រកម្ពុជាឆ្នាំ២០០៧ ទទួលស្គាល់នូវសិទ្ធិសន្តតិកម្មរបស់ សហព័ទ្ធដោយត្រូវចូលរួមមកបែងចែកមត៌ករបស់មតកជនដែលសហព័ទ្ធគឺ ជាសន្តតិជនជានិច្ច ទោះជាក្នុងករណីមាន ឬក៏គ្មានសន្តតិជនទាំង៣លំដាប់ថ្នាក់ក៏ដោយ។

### ២.៤.១. ករណីសន្តតិជនមានតែសហព័ទ្ធ

ដូចដែលបានបកស្រាយនៅក្នុងចំណុច១.២.សន្តតិជនជានិច្ចខាងលើរួចមកហើយ ប្រសិនបើក្នុងករណីណាមួយដែលមតកជនគ្មាន នូវសន្តតិជនផ្សេងទៀត នោះសហព័ទ្ធនឹងត្រូវទទួលបានចំណែកមត៌កទាំងអស់តែម្នាក់ឯងគត់ លើកលែងក្នុងករណី ដែលសហព័ទ្ធធ្លាក់ទៅជាអភ័ព្វបុគ្គលឬបុគ្គល ដែលបានផ្តាច់ពីសន្តតិកម្ម។ នៅក្នុងករណីដែលមកជនមានសហព័ទ្ធ ទោះបីជាមាននូវសន្តតិជនដទៃតាមលំដាប់ណាមួយផងដែរ នោះយើងនឹងបែងចែកមត៌កតាមករណីខាងក្រោមៈ

### ២.៤.២. ករណីសន្តតិជនជាសហព័ទ្ធរួមជាមួយបច្ឆាញាតិ

ចំណុច ក នៃ **មាត្រា១១៦២** នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បានកំណត់អំពីសន្តតិជនមានភាពស្មើគ្នាក្នុងការទទួលបាននូវចំណែកមត៌ក ក្នុងករណីសហព័ទ្ធនិងកូនរបស់មតកជនជាសន្តតិជន។ ការកំណត់ដូច្នេះដោយសារតែការពិចារណាទៅដល់ការចំណាយសម្រាប់ការរស់នៅជាអាទិ៍ ក្រោយពេលដែលមតកជនទទួលមរណភាព។ ជាគោលការណ៍ទ្រព្យសម្បត្តិប្តីប្រពន្ធរកបានក្នុងរយៈពេលនៃអាពាហ៍ពិពាហ៍ចាត់ទុក ជាទ្រព្យរួមហេតុនេះនៅពេលសហព័ទ្ធណាមួយទទួលមរណភាពសហព័ទ្ធម្ខាងទៀតត្រូវទទួលបាននូវទ្រព្យសម្បត្តិពាក់កណ្តាលនៃទ្រព្យរួម ។

**ឧទាហរណ៍៖** មកតជន ក មានសហព័ទ្ធម្នាក់ឈ្មោះ ខ ព្រមទាំងកូនបង្កើតចំនួន២នាក់ គឺ គ និង ឃ និងកូនសុំចំនួនម្នាក់គឺ ង។ ក្នុងករណីនេះសហព័ទ្ធ និងកូនទាំងអស់ត្រូវទទួលបានចំណែកមត៌កស្មើៗគ្នាដោយម្នាក់ទទួលបាន១/៤(មួយភាគបួន)នៃមត៌កទាំងអស់។ ករណីសន្តតិកម្មជំនួសក៏ត្រូវបានយកមកអនុវត្តផងដែរ ប្រសិនបើសន្តតិជនទទួលមរណភាពជាដើម ដោយចំណែកមត៌ក របស់សន្តតិជនត្រូវបែងបែកឱ្យកូនស្មើៗគ្នា។

### ២.៤.៣. ករណីសន្តតិជនជាសហព័ទ្ធរួមជាមួយបុព្វញាតិ

ប្រសិនបើសហព័ទ្ធ និង បុព្វញាតិរបស់មតកជនជាសន្តតិជននោះ ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ កំណត់ថាសហព័ទ្ធទទួលបាន ១/៣ (មួយភាគបី) ឯចំណែកឪពុកម្តាយវិញទទួលបាន២/៣ (ពីរភាគបី)។ ប៉ុន្តែបើមកតជនមានតែឪពុក ឬ ម្តាយតែម្ខាងនៅរស់វិញនោះ សហព័ទ្ធ និង ឪពុកឬម្តាយដែលនៅរស់

នោះត្រូវទទួលបានចំណែកស្មើគ្នាគឺ ១/២ (មួយភាគពីរ) ។[24] វាជាករណីដែលកម្រមួយដែលមតកជនមានឪពុកម្ដាយច្រើនរូប(តាមរយៈសុំកូនធម៌តា) ចំណែករបស់សហព័ទ្ធគឺនៅតែ ១/៣ (មួយភាគបី)ដដែល តែចំណែករបស់ឪពុកម្ដាយវិញនោះគឺ២/៣ (ពីរភាគបី)ដោយតម្រូវឱ្យចែកគ្នាស្មើៗគ្នា។

**ឧទាហរណ៍៖** មតកជន ក មានសន្តតិជនជា សហព័ទ្ធ ខ ព្រមទាំងឪពុក គ ម្ដាយ ឃ និងឪពុកចិញ្ចឹម ង និងម្ដាយចិញ្ចឹម ច ។ នោះ ខ ត្រូវទទួលបានចំណែក ១/៣(មួយភាគបី) នៃមតិកសរុប។ ឯចំណែក ដែលនៅសល់ គឺ ២/៣ ត្រូវយកមកបែងចែកស្មើគ្នារវាង គ ឃ ង និង ច ដោយម្នាក់ ត្រូវទទួលបានចំណែក ២/១២ (ពីរភាគដប់ពីរ)។

ក្នុងករណីដែលមតកជនគ្មានឪពុកម្ដាយជាសន្តតិជននោះជីដូនជីតាត្រូវទទួលចំណែកបន្តសហព័ទ្ធរបស់មតកជនត្រូវទទួលបានចំណែកមត៌កពាក់កណ្ដាលនៃមត៌កសរុបទាំងមូល ដោយចំណែកសេសសល់ត្រូវបែងចែកឱ្យស្មើគ្នារវាងជីដូនជីតា។

**ឧទាហរណ៍៖** ក រៀបការជាមួយ ខ។ ហើយ ក មាន ជីដូនជីតា ខាងឪពុក ២នាក់ (តាង ដោយ គ និងឃ) និង ជីតាខាងម្ដាយ១នាក់ (តាងដោយ ង) ។ សន្មតថា ឪពុកម្ដាយរបស់ ក ទទួលមរណភាពហើយ។

➔សិក្សាទៅលើ ចំណែកមត៌ករបស់សន្តតិជនរបស់ ក ដោយ សន្តិជនរបស់ ក មាន ខ ដែលជាសហព័ទ្ធ និង គ ឃ ង ដែលជា ជីដូនជីតា យោងមាត្រា ១១៦២ នោះ ខ ត្រូវទទួលបានចំណែក ១/២ (មួយភាគ២)រីឯ គ ឃ និង ង ត្រូវបែងចែកចំណែក ១/២ ជាបីចំណែកស្មើគ្នា ដូចនេះម្នាក់ៗទទួលបានចំណែក ១/៦ (មួយភាគប្រាំមួយ)។

### ២.៤.៤. ករណីសន្តតិជនជាសហព័ទ្ធរួមជាមួយសាខាញាតិ

ក្នុងករណីដែលសន្តតិជនជាសហព័ទ្ធ និង បងប្អូនបង្កើត ឬសន្តតិជនជំនួស (ក្មួយប្រុសឬក្មួយស្រី) នោះចំណែកមត៌ករបស់សហព័ទ្ធគឺ ១/២ (មួយភាគពីរ) ចំណែកឯមត៌ករបស់សហសន្តតិជនដែលជាបងប្អូនគឺ ១/២ (មួយភាគពីរ) ត្រូវយកមកចែកឱ្យសហសន្តតិជនថ្នាក់ទី៣ទាំងនោះស្មើៗគ្នា។[25] ក្នុងករណីនេះសន្តតិកម្មជំនួសក៏ត្រូវបានយកមកអនុវត្តផងដែរ តែអនុវត្តបានតែមួយថ្នាក់តែប៉ុណ្ណោះ។ **ឧទាហរណ៍៖** ករណីសន្តតិជនលំដាប់ទី៣ជាអ្នកទទួលមត៌កជាមួយនឹងសហព័ទ្ធ។ មតកជន ក មានសន្តតិជន ជាសហព័ទ្ធ ខ និងបងប្អូនបង្កើត ង និងបងប្អូនរួមឪពុកចំនួន២នាក់គឺ ឆ និង ជ។

សន្តតិកម្មត្រូវបានបែងចែកជាចំណែកដូចខាងក្រោម៖

ខ ត្រូវទទួលបានចំណែក ១/២ (មួយភាគពីរ)ចំណែកដែលនៅសល់ ពាក់កណ្ដាលទៀត ត្រូវយកមកឱ្យ ង ឆ និង ជ ។ ប៉ុន្តែ ឆ និង ជ ត្រូវទទួលបានតែពាក់កណ្ដាលនៃ ង ប៉ុណ្ណោះដោយហេតុថាជាបងប្អូនរួមតែឪពុក។ នោះ ង ត្រូវទទួលបាន ១/៤(មួយភាគបួន) ឯចំណែករបស់ ឆ និង ជ ត្រូវបាន ១/៨(មួយភាគប្រាំបី) ស្មើៗគ្នា។

[24] មាត្រា១១៦២(ខ) នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[25] មាត្រា១១៦២(គ) នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ប្រសិនបើសន្តតិជនណាមួយទទួលមរណភាពឬបាត់បង់សិទ្ធិទទួលសន្តតិកម្មដោយប្រការណាមួយ នោះកូនរបស់សន្តតិជននឹងត្រូវទទួលចំណែករបស់សន្តតិជននោះ។ ឧទាហរណ៍ថា ង ទទួល មរណភាព ដោយមានកូនបីនាក់ទទួលសន្តតិកម្មជំនួស នោះចំណែករបស់ ង ១/៤ នោះត្រូវបែង ចែកជាបីស្មើៗគ្នាដល់កូនទាំងបីគឺ ១/១២ (មួយភាគដប់ពីរ)។

## ផ្នែកទី៣៖ ការសម្រួលចំណែកមតក៌

## ៣.១. ការសម្រួលចំណែកមត៌ក

ការសម្រួលចំណែកមត៌កធ្វើឡើង ដើម្បីឱ្យមានសមភាពរវាងសន្តតិជននឹងសន្តតិជនក្នុងការទទួលបានចំណែកមត៌កឱ្យសមស្របទៅនឹងភាពជាក់ស្តែងដូចជាក្នុងករណីមានសន្តតិជនទទួលបានផលប្រយោជន៍ពិសេសពីមត៌កជននិងសន្តតិជនដែលបានធ្វើវិភាគទានជូនមត៌កជននៅពេលមានជីវិត។ សន្តតិជនត្រូវតែទទួលបានចំណែកមត៌កស្មើរៗគ្នា ដូចនេះយើងត្រូវតែសិក្សាយល់ឱ្យច្បាស់នូវចំណែកដែលសន្តតិជនបានទទួលផលប្រយោជន៍ពិសេសថាគួរទទួលបានបន្ថែមឬយ៉ាងណា ព្រមទាំងសិក្សាពីការសម្រួលចំណែកមត៌កដើម្បីកុំឱ្យបំពានទៅដល់ចំណែកសិទ្ធិរបស់សន្តតិជនដទៃទៀត និងស្វែងយល់ពីករណីដែលមានសន្តតិជនបានធ្វើវិភាគទានជូនមតកជនកាលនៅរស់។

## ៣.២. ផលប្រយោជន៍ពិសេស

ផលប្រយោជន៍ពិសេសគឺជាទ្រព្យដែលបុគ្គលជាសន្តតិជនទទួលជាប្រទានកម្ម នៅក្នុងឱកាសអាពាហ៍ពិពាហ៍ឬហេតុការណ៍ផ្សេងទៀតឬដើម្បីមូលធននៃជីវភាពរស់នៅ ឬដែលបានទទួលជាអច្ច័យទានពីមតកជន។[26] ផលប្រយោជន៍ពិសេសអាចស្តែងចេញពីការទទួលប្រទានកម្មជាវត្ថុ ជាប្រាក់ ពីមតកជនកាលដែលនៅរស់រានមានជីវិតទៅកាន់សន្តតិជន។

ដើម្បីធ្វើការសម្រួលចំណែកមត៌ក យើងត្រូវយកតម្លៃមត៌កនៅថ្ងៃបើកសន្តតិកម្មបូកបញ្ចូលនឹងផលប្រយោជន៍ពិសេសនោះយើងនឹងឃើញចំនួនមត៌កសរុបហើយចំណែកដែលនៅសល់ពីការដកតម្លៃនៃប្រទានកម្មឬអច្ច័យទាននោះជាចំណែករបស់អ្នកទទួលបានផលប្រយោជន៍ពិសេស។

[26] មាត្រា១១៦៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

**រូបមន្ត៖ មត៌កសរុប= មត៌កថ្ងៃបើកសន្តតិកម្ម + ផលប្រយោជន៍ពិសេស**
**ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស= (មត៌កសរុប/ចំនួនសន្តតិជន) - ផលប្រយោជន៍ពិសេស**

### ៣.២.១ ករណីផលប្រយោជន៍មានតម្លៃតិចជាងចំណែកមត៌ក

ក្នុងករណីសន្តតិជនទទួលបានផលប្រយោជន៍ពិសេសប៉ុន្តែមានតម្លៃតិចជាងចំណែកមត៌ក សន្តតិជននោះនៅតែអាចទទួលបានចំណែកមត៌កបន្ថែម ដើម្បីបង្គ្រប់នូវចំណែកមត៌ករបស់សន្តតិជននោះ។

**ឧទាហរណ៍៖** Y បានទទួលមរណៈភាពហើយបន្សល់ទុកមត៌ក 4000ដុល្លារឱ្យ A B C ហើយ B បានទទួលផលប្រយោជន៍ពិសេសពីមតកជនកាលនៅរស់ចំនួន 500ដុល្លារ។ ចូរគណនាចំណែកមត៌ករបស់សន្តតិជននីមួយៗ។

នៅក្នុងករណីខាងលើ យោងតាមមាត្រា ១១៦៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ យើងត្រូវយកចំណែកមត៌កថ្ងៃបើកសន្តតិកម្មចំនួន 4000ដុល្លារ បូកនឹង ផលប្រយោជន៍ពិសេសចំនួន 500 ដុល្លារ នោះយើងទទួលបានមត៌កសរុបចំនួន 4500 ដុល្លារ។

A B C ត្រូវទទួលបានចំណែកមត៌កស្មើៗគ្នាដោយម្នាក់ៗត្រូវទទួកបានចំណែកមត៌កចំនួន1/3(មួយភាគបី) នៃចំនួនមត៌កចំនួន4500ដុល្លារនាំឱ្យម្នាក់ៗត្រូវទទួលបាន1500ដុល្លារប៉ុន្តែដោយសារBបានទទួលផលប្រយោជន៍ពិសេសពីមតកជនកាលនៅរស់ចំនួន500ដុល្លារ

ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស(B)= (4500÷3)−500=1000 ដុល្លារ

ដូចនេះនៅថ្ងៃបើកសន្តតិកម្ម B ទទួលបានតែ1000ដុល្លារប៉ុណ្ណោះ រីឯ A ទទួល បាន1500ដុល្លារ និង C ទទួលបាន 1500ដុល្លារ។

### ៣.២.២. ករណីផលប្រយោជន៍មានតម្លៃស្មើរនឹងចំណែកមត៌ក

ក្នុងករណីសន្តតិជនទទួលបានផលប្រយោជន៍ពិសេសហើយមានតម្លៃស្មើរនឹងចំណែកមត៌ក សន្តតិជននោះមិនអាចទទួលបានចំណែកមត៌កទៀតទេ។[27]

**ឧទាហរណ៍៖** Y បានទទួលមរណៈភាពហើយបន្សល់ទុកមត៌ក 1000 ដុល្លារឱ្យ A B C ហើយ B បានទទួលផលប្រយោជន៍ពិសេស ពីមតកជនកាលនៅរស់ចំនួន500ដុល្លារ។

នៅក្នុងករណីខាងលើ មត៌កថ្ងៃបើកសន្តតិកម្មមានចំនួន 1000 ដុល្លារ បូកនឹងផលប្រយោជន៍ពិសេសរបស់B ចំនួន 500ដុល្លារ នោះនាំឱ្យមត៌កសរុបគឺ 1500ដុល្លារ។ តាមគោលការណ៍សហសន្តតិជនត្រូវទទួលបានចំណែកមត៌កស្មើរៗគ្នា ដោយ A B និង C ត្រូវទទួលបាន 1/3 ដែលស្មើរ នឹង 500 ដុល្លារ ក្នុងមួយនាក់។ ប៉ុន្តែ

[27] មាត្រា១១៦៣ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ដោយ B បានទទួលផលប្រយោជន៍ពិសេសចំនួន 500ដុល្លារ រួចមកហើយដែលមាន តម្លៃស្មើរនឹងចំណែកមត៌ក។ ដូចនេះ B មិនអាចទទួលបានចំណែកមត៌កទៀតនោះទេ។

សរុបមក នៅថ្ងៃបើកសន្តតិកម្មៈ

A ទទួលបាន 500ដុល្លារ

B ទទួលបាន 0ដុល្លា

C ទទួលបាន 500ដុល្លារ។

### ៣.២.៣ ករណីផលប្រយោជន៍មានតម្លៃលើសនៃចំណែកមត៌ក

យោងតាម**មាត្រា ១១៦៥** នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧បានចែងថាករណីដែលតម្លៃដែលទទួលបានផលប្រយោជន៍ពិសេសនោះលើសពីតម្លៃនៃចំណែកមត៌កសហសន្តតិជន នោះពុំចាំបាច់បង្វិលមកវិញ នោះទេ។

**<u>ឧទាហរណ៍</u>៖** Y បានទទួលមរណៈភាពហើយបន្សល់ទុកមត៌កចំនួន 2000 ដុល្លារឱ្យ A B C ដែលជាសន្តតិជនរបស់គាត់ហើយកាល Y នៅរស់បានឱ្យប្រាក់ចំនួន 2000ដុល្លារដើម្បីប្រកបរបររកស៊ី។

នៅក្នុងករណីខាងលើ មត៌កថ្ងៃបើកសន្តតិកម្មចំនួន 2000 ដុល្លារ បូកនឹងផលប្រយោជន៍ពិសេសចំនួន 2000 ដុល្លារ នាំឱ្យមត៌កសរុបគឺ 4000$។

ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស (B)គឺ (4000÷3)-2000= -666.66 ដុល្លារ (លើសចំណែក) យោងតាមមាត្រា១១៦៣ កថាខណ្ឌទី២និង មាត្រា១១៦៥ B មិនអាចទទួលបានចំណែកមត៌កបន្ថែមទៀតនោះទេព្រមទាំងមិនចាំបាច់បង្វិលចំណែកដែលលើសនោះមកវិញទេ។

ចំណែកឯ A និង C ត្រូវទទួលបានចំណែកមត៌កតាមសមាមាត្រនៃមត៌កជាក់ស្តែងដែលមានចំនួន 2000 ដុល្លារ ដោយបាន 1000 ដុល្លារក្នុងមួយនាក់។

សរុបមក A ទទួលបាន 1000ដុល្លារ

B ទទួលបាន 0 ដុល្លារ

C ទទួលបាន 1000 ដុល្លារ។

### ៣.២.៤.តម្លៃប្រទានកម្ម

- "**ប្រទានកម្ម**"ជាកិច្ចសន្យាដែលភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ឱ្យទៅភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិ ដោយមិនយកថ្លៃ ហើយ ភាគីម្ខាងទៀតយល់ព្រមទទួល។[28]
- "**បដិគ្គាហក**" ជាអ្នកទទួលទ្រព្យពីទាយក។

[28] សទ្ទានុក្រម ផ្នែករដ្ឋប្បវេណី នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ទំព័រ១៤

- **"ទាយក"** ជាអ្នកអោយទ្រព្យទៅភាគីម្ខាងទៀតដោយមិនគិតថ្លៃ។

តម្លៃនៃប្រទានកម្ម ជាមូលដ្ឋាននៃការគណនាក្នុងករណីមានសន្តតិជនទទួលបានផលប្រយោជន៍ពិសេស ថាតើគួរយកតម្លៃនៅពេលចាត់ចែងឬពេលដែលបាត់បង់។ តម្លៃប្រទានកម្មក៏ជាមូលដ្ឋានក្នុងការគណនាភាគបម្រុង ផងដែរក្នុងករណីប្រទានកម្មនោះបានធ្វើឡើងក្នុងអំឡុងពេលមួយឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម។[29]

តម្លៃដែលត្រូវយកមកគណនាចំពោះ ប្រទានកម្មដែលបានចាត់ចែងហើយ ត្រូវគិតដូចខាងក្រោម៖

- បើបដិគ្គាហកបានចាត់ចែងទ្រព្យដែលទទួលបានដោយប្រទានកម្មហើយត្រូវបានវិនាស ឬបាត់បង់នៅមុន ថ្ងៃបើកសន្តតិកម្ម នោះតម្លៃដែលត្រូវយកមកគណនា គឺយកតម្លៃនៅពេលដែលបាត់បង់ ឬវិនាសនោះ។
- បើបដិគ្គាហកបានចាត់ចែងទ្រព្យដែលទទួលបានដោយប្រទានកម្មហើយតម្លៃប្រទានកម្មនោះបានកើន ឡើងនោះតម្លៃដែលត្រូវយកមកគណនា គឺយកតម្លៃដើមនៃប្រទានកម្មនោះ។
- ចំពោះការប្រាក់ ឬផលចំណេញដែលកើតចេញពីប្រទានកម្មនោះ មិនត្រូវយកមកគណនានោះទេ។[30]

**<u>ឧទាហរណ៍៖</u>** មតកជន A កាលនៅរស់បានផ្តល់ប្រទានកម្មឱ្យកូនទី1នូវឡានមួយគ្រឿងដែលមានតម្លៃ 30000 ដុល្លារ និងអោយ កូនទី2 នូវដីដែលមានតម្លៃ20000 ដុល្លារនិងអោយ កូនទី3 នូវលុយចំនួន10000 ដុល្លារ។ ពេល A បានទទួលមរណៈភាពបានបន្សល់ទុកមត៌កចំនួន 20000ដុល្លារ។ នៅថ្ងៃបើកសន្តតិកម្ម តម្លៃឡានរបស់ កូនទី1 ក៏ធ្លាក់ចុះសល់ត្រឹម 15000 ដុល្លារចំណែកឯដីរបស់ កូនទី2 ឡើងតម្លៃដល់ 40000ដុល្លារ រីឯលុយរបស់ កូនទី3បានយកទៅរកស៊ីកើនដល់ 30000 ដុល្លារ។

- ការគណនាតម្លៃប្រទានកម្មនៃឡានរបស់កូនទី1គឺ ត្រូវយកតម្លៃនៅថ្ងៃបើកសន្តតិកម្មដែលនៅសល់ 15000 ដុល្លារ
- ការគណនាតម្លៃប្រទានកម្មនៃដីរបស់កូនទី2គឺ ត្រូវយកតម្លៃនៅថ្ងៃអោយប្រទានកម្មដែលមានតម្លៃ 20000 ដុល្លារ
- ការគណនាតម្លៃប្រទានកម្មនៃលុយរបស់កូនទី3 គឺយកតម្លៃនៅថ្ងៃដែលបានអោយប្រទានកម្មដែលមានតម្លៃ 10000 ដុល្លារ។

## ៣.៣. ភាគនៃវិភាគទាន

ក្នុងចំណោមសហសន្តតិជនទាំងអស់ បើមានសន្តតិជនណាដែលបានធ្វើសកម្មភាពចំណាយពេលវេលា ថវិការ ដើម្បីមើលថែរក្សាមតកជនកាលនៅរស់រានមានជីវិត ឬបានមើលថែទាំព្យាបាលមតកជន ឬបានជួយគ្រប់

[29] មាត្រា១២៣២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[30] មាត្រា១១៦៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

គ្រងមើលការខុសត្រូវលើទ្រព្យសម្បត្តិមតកជន ឬជួយបង្កើនទ្រព្យរបស់មតកជននោះមានន័យថាសន្តតិជនបានធ្វើវិភាគទានជូនមតកជន។

ភាគនៃវិភាគទានធ្វើឡើងដើម្បីជួយសម្រួលអោយមានសមភាពរវាងសន្តតិជនដែលបានចំណាយធនធនរបស់ខ្លួនដើម្បីធ្វើវិភាគទានជូនមតកជនកាលនៅមានជីវិត និងសន្តតិជនដែលមិនបានធ្វើវិភាគទានជូនមតកជន។ សកម្មភាពដែលចាត់ទុកថាជាភាគនៃវិភាគទាន ដើម្បីថែរក្សា ឬ បង្កើនទ្រព្យសម្បត្តិរបស់មតកជនមានដូចជាៈ

- **ការផ្តល់សេវកម្មលើកិច្ចការរបស់មតកជន**ៈសន្តតិជនបានជួយមតកជនក្នុងការមើលថែរក្សាមុខរបរ ជំនួញ ជួយ បំពេញភារកិច្ចជំនួសនៅពេលមតកជនមិនអាចធ្វើកិច្ចការទាំងនោះដោយខ្លួនឯងបាន។
- **ការផ្តល់តាវកាលិកលើទ្រព្យសម្បត្តិមតកជនៈ**សន្តតិជនបានជួយថែរក្សាទ្រព្យរបស់មតកជនឱ្យនៅឋិតថេរ ឬធ្វើឱ្យមានការកើនឡើង មិនធ្វើឱ្យមានការខូចខាត ឬខាតបង់ឡើយ។
- **ការថែទាំព្យាបាលមតកជនៈ**សន្តតិជនបានចំណាយពេលវេលាឬថវិការដើម្បីមើលថែ ព្យាបាលមតកជន។

**ឧទាហរណ៍ៈ** មីងរី បានទទួលមរណភាពដោយមុនពាលគាត់ទទួលមរណភាពប្តីរបស់មីងរីបានចំណាយប្រាក់អស់ ១០០០០ ដុល្លារដើម្បីមើលថៃព្យាបាលជម្ងឺមីងរី។ ចំណែកឯកូនទី១របស់មីងរីបានចំណាយពេលជួយដល់ មុខរបររកស៊ីរបស់មីងរីដែលជាម្តាយហើយនៅពេលមីងរីធ្លាក់ខ្លួនឈឺ កូនទី១ របស់មីងរីក៏នៅតែមើលថែមុខរបរនោះមិនឱ្យមានការខាតបង់នោះទេ។ រីឯ កូនទី២ របស់មីងរីបានចំណាយប្រាក់សាងសង់បន្ទប់ថ្មីឱ្យមីងរីអស់ ២០០០ ដុល្លារដើម្បីកុំឱ្យមីងរីពិបាកឡើងចុះ។

- ប្តីមីងរីបានចំណាយប្រាក់ចំនួន ១០០០០ ដុល្លារក្នុងការមើលថៃ ព្យាបាល មីងរីជាភាគនៃវិភាគទានក្នុងការថែទាំ ព្យាបាលមីងរី(មតកជន)។
- កូនទី១ របស់មីងរីបានចំណាយពេលវេលាជួយមើលថែដល់មុខរបររបស៊ីរបស់មីងរី មិនឱ្យមានការខាតបង់ជាភាគ នៃវិភាគទានក្នុងការផ្តល់សេវកម្មលើកិច្ចការរបស់មតកជន។
- កូនទី២របស់មីងរី បានចំណាយប្រាក់ ២០០០ ដុល្លារ សាងសង់បន្ទប់ថ្មីឱ្យមីងរីជាភាគនៃវិភាគទានក្នុងការផ្តល់តាវកាលិកលើទ្រព្យសម្បត្តិមតកជន។

**រូបមន្តៈ មត៌កជាក់ស្តែង= មតក៌ពេលចាប់ផ្តើមបើកសន្តតិកម្ម - វិភាគទាន**
**ចំណែកមត៌ករបស់អ្នកធ្វើវិភាគទាន= (មត៌កជាក់ស្តែងៈ ចំនួនសន្តតិជន) + ភាគវិភាគទាន**

ការសម្រួលចំណែកមត៌កក្នុងករណីមានសន្តតិជនបានធ្វើវិភាគទាន ត្រូវយកទ្រព្យសម្បត្តិរបស់មតកជននៅថ្ងៃបើកសន្តតិកម្មដកនឹងតម្លៃភាគនៃវិភាគទាន។រីឯចំណែកមត៌ករបស់សន្តតិជនដែលបានធ្វើវិភាគទានត្រូវយកចំណែកដែលត្រូវទទួលបានក្នុងថ្ងៃបើកសន្តតិកម្ម បូកបន្ថែមនឹងតម្លៃភាគនៃវិភាគទាន។

ការកំណត់តម្លៃភាគនៃវិភាគទាន អាចធ្វើទៅបានដោយការពិភាក្សាគ្នារវាងសហសន្តតិជន។ បើសិនការ

ពិភាក្សានោះមិនមានការចុះសម្រុងគ្នានោះទេ សហសន្តតិជនអាចដាក់ពាក្យទៅកាន់តុលាការសុំឱ្យតុលាការធ្វើការកំណត់តម្លៃភាគនៃវិភាគទាន។

**ឧទាហរណ៍៖** លោក ក បានទទួលមរណភាពបន្សល់ទុកមត៌ក ២៥០០ ដុល្លារ ឲកូន ៣ នាក់។ កូនទី១បានធ្វើវិភាគទានជូន លោក ក កាលនៅរស់អស់៥០០ដុល្លារ រីឯកូនទី២ បានធ្វើវិភាគទានឲលោក ក អស់៨០០ដុល្លារ។

- មត៌កជាក់ស្តែង = ២៥០០ - (៥០០+៨០០) = ១២០០ ដុល្លារ
- ចំណែកមត៌ករបស់សន្តតិជនម្នាក់ៗទទួលបាន១/៣ នៃ ១២០០ ដុល្លារស្មើរនឹង ៤០០ ដុល្លារក្នុងម្នាក់
- ចំណែកមត៌ករបស់សន្តតិជនដែលបានធ្វើវិភាគទានគឺបាន ១/៣ នៃ១២០០ដុល្លារបូកបន្ថែមនឹងតម្លៃវិភាគទាន។

ដូចនេះ ចំណែកមត៌ករបស់កូនទី១ គឺ ៤០០ + ៥០០ = ៩០០ ដុល្លារ

ចំណែកមត៌ករបស់កូនទី២ គឺ ៤០០ + ៨០០ = ១២០០ ដុល្លារ

ចំណែកមត៌ករបស់កូនទី៣ គឺ ៤០០ ដុល្លារ។

❖ **ករណីមានវិភាគទាន និង ផលប្រយោជន៍ពិសេសក្នុងពេលតែមួយ**

**ឧទាហរណ៍៖** លោក ក បានទទួលមរណភាពហើយបន្សល់ទុកមត៌កចំនួន ១៥០០០ដុល្លារទុកឱ្យកូនរបស់គាត់ចំនួន ៣ នាក់ A B C ។ កាលលោក ក នៅរស់ លោក ក បានឱ្យលុយទៅ A ចំនួន ៥០០០ ដុល្លារ និងបានទិញម៉ូតូឱ្យ C ដែលមាន តម្លៃ ៣០០០ ដុល្លារ។ រីឯ B បានចំណាយប្រាក់របស់ខ្លួនអស់ ៩០០០ ដុល្លារដើម្បីព្យាបាលលោក ក ។

មត៌កសរុប= ១៥០០០+៥០០០+៣០០០-៩០០០= ១៤០០០ដុល្លារ

- ចំណែកមត៌ករបស់ A = (១៤០០០ ៖ ៣ ) - ៥០០០ = -៣៣៣.៣៣ ដុល្លារ
- ចំណែកមត៌ករបស់ B = (១៤០០០ ៖ ៣ ) + ៩០០០ = ១៣៦៦៦.៦ ដុល្លារ
- ចំណែកមត៌ករបស់ C = (១៤០០០ ៖ ៣ ) - ៣០០០ = ១៦៦៦.៦ ដុល្លារ

ទោះបីជា A ទទួលបានផលប្រយោជន៍លើសចំណែកមត៌កក៏ដោយ A មិនចាំបាច់បង្វិលមកវិញ នោះទេហើយក៏មិនបានចំណែកមត៌កបន្ថែមនៅថ្ងៃបើកសន្តតិកម្មដែរ។មត៌កនៅថ្ងៃបើកសន្តតិកម្ម១៥០០០ដុល្លារ ត្រូវបែងចែកឱ្យBនិងCដោយយកចំនួនមត៌កថ្ងៃបើកសន្តតិកម្ម គុណនឹង ចំណែកសិទ្ធិខ្វះរបស់សន្តតិជនហើយចែកនឹងចំណែកខ្វះសរុប។

- ចំណែកមត៌ករបស់ B = ( ១៥០០០ x ១៣៦៦៦.៦ ) ៖ ១៥៣៣៣.២ = ១៣៣៦៩.៦១ ដុល្លារ
- ចំណែកមត៌ករបស់ C = ( ១៥០០០ x ១៦៦៦.៦ ) ៖ ១៥៣៣៣.២ = ១៦៣០.៣៨ ដុល្លារ

## ៣.៤. ភាគបម្រុង

ភាគបម្រុងគឺជារបបដែលជួយធានាក្នុងការសម្របសម្រួលសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍ដើម្បីកុំឱ្យមានការបំពានចំណែកសិទ្ធិមត៌ករបស់សន្តតិជន។ ភាគបម្រុងជាវិធានធានាមិនឱ្យមានការបំពានលើចំណែកស្របច្បាប់ដល់អ្នកដែលមានសិទ្ធិទទួលបានមត៌ក ក្នុងករណីដែលមតកជនបានបង្ហាញឆន្ទៈរបស់ខ្លួនក្នុងការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនទៅឱ្យអ្នកដទៃដែលមិនមែនជាសន្តតិជន ឬបែងចែកលើសលុបទៅឱ្យសន្តតិជនណាមួយហើយសន្តតិជនដទៃទៀតទទួលបានចំណែកតិចតួចដែលធ្វើឱ្យមិនមានសមភាព។

### ៣.៤.១ ទ្រព្យជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

ភាគបម្រុងគឺជា ចំណែកបម្រុងទុកសម្រាប់អ្នកដែលមានសិទ្ធិលើភាគបម្រុងតាមច្បាប់ដែលរួមមានទ្រព្យសម្បត្តិនៅថ្ងៃបើកសន្តតិកម្ម តម្លៃនៃទ្រព្យសម្បត្តិប្រទានកម្ម តម្លៃនៃផលប្រយោជន៍ពិសេស និង កាតព្វកិច្ចដែលជាទ្រព្យមូលដ្ឋាន ក្នុងការគណនាភាគបម្រុង។[31]

❖ **ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង**

ផលប្រយោជន៍ពិសេសដែលបានចែងក្នុង **មាត្រា១១៦៣** នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ត្រូវបានលើកលែងរីឯប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុងបានកំណត់ដូចខាងក្រោម៖

- ប្រទានកម្មដែលបានធ្វើអំឡុងពេល ១ ឆ្នាំ មុនពេលចាប់ផ្តើមសន្តតិកម្ម[32]
- ប្រទានកម្មដែលធ្វើឡើងដោយភាគីទាំងសងខាងដែលបានដឹងថានឹងមានការខូចខាតដល់ អ្នកមានសិទ្ធិលើភាគបម្រុង ចំណុចនេះមិនគិតពីរយៈពេលនោះទេ។[33]

### ៣.៤.២. អ្នកមានសិទ្ធិលើភាគបម្រុង

អ្នកមានសិទ្ធិលើភាគបម្រុងដែលច្បាប់បានកំណត់មានដូចជា៖

- បច្ឆាញាតិផ្ទាល់ ឬ សន្តតិជនជំនួសរបស់ខ្លួន
- ឪពុកម្តាយ ឬ ជីដូនជីតា
- សហព័ទ្ធ។

❖ **សម្គាល់**

1. សហព័ទ្ធមានសិទ្ធិលើភាគបម្រុងជានិច្ច

[31] មាត្រា ១២៣១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[32] មាត្រា១២៣២ ចំណុច ក នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[33] មាត្រា១២៣២ ចំណុច ខ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

2. ជនដែលបានរៀបរាប់ខាងលើមិនប្រាកដថាមានសិទ្ធិលើភាគបម្រុងទេ ពោលគឺកំណត់ទៅតាមលំដាប់សន្តតិជនបើសន្តតិជនលំដាប់ទី១ជាអ្នកមានសិទ្ធិលើភាគបម្រុងនោះសន្តតិជនលំដាប់ទី២ មិនមានសិទ្ធិលើភាគបម្រុងនោះទេ។

**ជាទូទៅភាគបម្រុងត្រូវបានកំណត់ដូចខាងក្រោម៖**

- ១/៣នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីមានសន្តតិជនជាឪពុកម្តាយ ឬ ជីដូនជីតាប៉ុណ្ណោះ[34]
- ១/២ នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីផ្សេងៗដូចជា៖
  - បច្ឆាញាតិផ្ទាល់ ចំណែកនៃភាគបម្រុងគឺ ១/២ ក្នុងចំណោមបច្ឆាញាតិផ្ទាល់បានចំណែកស្មើរៗគ្នា
  - ករណីមានតែសហព័ទ្ធ ចំណែកនៃភាគបម្រុងគឺ ១/២
  - ករណីមានបច្ឆាញាតិផ្ទាល់និងសហព័ទ្ធ ចំណែកនៃភាគបម្រុងគឺ១/២ បច្ឆាញាតិផ្ទាល់និងសហព័ទ្ធនឹងទទួលបានចំណែកស្មើៗគ្នា
  - ករណីសហព័ទ្ធនិងឪពុកម្តាយ ចំណែកនៃភាគបម្រុងគឺ១/២ សហព័ទ្ធនិងឪពុកម្តាយនឹងទទួលបានចំណែកស្មើៗគ្នា
  - ករណីសហព័ទ្ធនិងជីដូនជីតា ចំណែកនៃភាគបម្រុងគឺ១/២ សហព័ទ្ធនិងជីដូនជីតានឹងទទួលបានចំណែកស្មើៗគ្នា

- ក្នុងករណីមានសន្តតិជនជំនួសភាគបម្រុងក៏ត្រូវចែកស្មើគ្នារវាងអ្នកដែលទទួលសន្តតិកម្មជំនួសដែរ។

**ឧទាហរណ៍១ ៖** លោក A ជាមតកជនមានកូនប្រុស B និង C ជាសហព័ន្ធ។ ក្នុងករណីនេះ សន្តតិជនរបស់ លោក A មានតែកូនប្រុស B និង C ជាសហព័ន្ធប៉ុណ្ណោះនាំឲចំណែកភាគបម្រុងគឺ ១/២ ដែល B នឹងទទួលបាន ១/៤ ហើយ C ទទួលបាន ១/៤។

**ឧទាហរណ៍២៖** មតកជន A មិនមានកូននិងសហព័ន្ធឡើយគឺមានតែឪពុកម្តាយប៉ុណ្ណោះជាសន្តតិជន។ ចំណែកភាគបម្រុងគឺ ១/៣ ហើយយកចំណែក១/៣នោះមកចែកជា ២ នោះ ឪពុកបាន ១/៦ រីឯម្តាយបាន ១/៦។

**ឧទាហរណ៍៣ ៖** ក្នុងករណីមតកជន A មានសហព័ន្ធ C និង ឪពុកម្តាយ ជាសន្តតិជន ចំណែកភាគបម្រុងគឺ ១/២ ដោយសន្តតិជនមាន ៣នាក់ នាំឲចំណែកសិទ្ធិលើភាគបម្រុងរបស់សន្តតិជននីមួយៗទទួលបាន១/៦។

### ៣.៤.៣. ការគណនាភាគបម្រុង

ក្នុងករណីមតកជនបានធ្វើប្រទានកម្មទ្រព្យសម្បត្តិយ៉ាងច្រើនដើម្បីជៀសវាងពីប្រព័ន្ធភាគបម្រុង ហេតុនេះទើបការ គណនាភាគបម្រុងត្រូវរាប់បញ្ចូលទាំងប្រទានកម្មនិង តម្លៃនៃផលប្រយោជន៍ពិសេសផងដែរ។

**រូបមន្ត៖ ភាគបម្រុង = ទ្រព្យសម្បត្តិនៅថ្ងៃបើកសន្តតិកម្ម + ប្រទានកម្ម + ផលប្រយោជន៍ពិសេស - កាតព្វកិច្ច**

[34] មាត្រា ១២៣០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

- **កាតព្វកិច្ច៖** ជាចំណងតាមផ្លូវច្បាប់ដែលចងបុគ្គលពីរនាក់ដោយឱ្យបុគ្គលម្នាក់ដែលបានកំណត់ហៅថា "**កូនបំណុល**" មានករណីកិច្ចចំពោះបុគ្គលម្នាក់ទៀតហៅថា "**ម្ចាស់បំណុល**"។[35] កាតព្វកិច្ចករណីនេះក៏រាប់បញ្ចូលទាំងសោហ៊ុយចំណាយលើបុណ្យសពរបស់មតកជនដែរ។[36]

**ឧទាហរណ៍៖** មតកជន A មានកូន ៣ នាក់ B C D។ កាលមតកជននៅរស់បានអោយប្រាក់ចំនួន ១០០០$ ទៅ B ដើម្បីធ្វើជាទុនទៅរកស៊ីនិងបានទិញម៉ូតូតម្លៃ ២៥០០$ អោយ D និង អោយប្រាក់លើកទឹកចិត្តទៅកាន់ក្មួយស្រីពេលប្រឡងចប់ចំនួន ៥០០$ មុនមតកជន A ទទួលមរណភាព ៣ខែ។ មតកជន A បានបន្សល់ទ្រព្យសម្បត្តិចំនួន ១៥០០០$ និង បំណុល ៤០០០$។

យោងតាមមាត្រា១២៣១

**ទ្រព្យសម្បត្តិមូលដ្ឋាននៃភាគបម្រុង**=១៥០០០+១០០០+២៥០០+៥០០-៤០០០ =១៥០០០$

យោងតាមមាត្រា១២៣០ ភាគបម្រុងដែលត្រូវធានាឱ្យសន្តតិជនស្មើនឹង ១/២ នៃទ្រព្យមូលដ្ឋានរបស់មតកជន

➔ ចំណែកភាគបម្រុង= ១៥០០០៖២= ៧៥០០$

ចំណែកភាគបម្រុងនៃសន្តតិជននីមួយៗ= ៧៥០០៖៣= ២៥០០$

ដូចនេះ សន្តតិជន B C Dមានសិទ្ធិលើចំណែកភាគបម្រុងចំនួន ២៥០០$ក្នុងមួយនាក់។

ចំនួនដែលបំពានភាគបម្រុងគឺ ត្រូវគណនាដោយយកភាគបម្រុងរបស់សន្តតិជន ដក នឹងចំនួនសរុបនៃទ្រព្យដែលទទួលបាននៅថ្ងៃបើកសន្តតិកម្មនិងផលប្រយោជន៍ពិសេសបូកនឹង ចំនួននៃទឹកប្រាក់កាតព្វកិច្ចដែលត្រូវទទួលបន្ទុក។[37]

### ៣.៤.៤. ការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយ

សិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងត្រូវរលត់អាជ្ញាយុកាលបើអំឡុងពេល១ឆ្នាំ បានកន្លងហួសទៅគិតចាប់ពីពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានដឹងពីការចាប់ផ្តើមសន្តតិកម្ម និងការកំណត់ចំណែកមត៌ក អច្ច័យទាន ប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេសដែលត្រូវកាត់បន្ថយ។ សិទ្ធិទាមទារឱ្យកាត់បន្ថយក៏ត្រូវរលត់ដោយអាជ្ញាយុកាល ៥ ឆ្នាំបានកន្លងផុតទៅគិតចាប់ពីថ្ងៃចាប់ផ្តើមសន្តតិកម្ម។[38] ចំពោះសន្តតិជនដែលទទួលបានប្រទានកម្ម ឬផលប្រយោជន៍ពិសេសអាចបដិសេធនូវការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

[35] សន្ទានុក្រម ផ្នែករដ្ឋប្បវេណី ទំព័រ ៦

[36] មាត្រា ១២៣១ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[37] មាត្រា១២៣៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[38] មាត្រា១២៤៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

បានបើសិនការទទួលផលប្រយោជន៍ពិសេសឬប្រទានកម្មនោះមានរយៈពេលលើសពី២០ឆ្នាំ នៅមុនថ្ងៃបើកសន្តតិកម្ម។[39]

## ផ្នែកទី៤៖ ការយល់ព្រមទទួល ឬបោះបង់ចំណែកសន្តតិកម្ម

នៅក្នុងផ្នែកទី៤នេះ យើងនឹងធ្វើការបកស្រាយទៅលើ ការយល់ព្រមទទួល ឬបោះបង់សន្តតិកម្ម ដែលសន្តតិជនអាចអនុវត្តទៅលើសន្តិកម្មដែលខ្លួនមានចំណែកទទួលបាន។ ដោយសន្តតិកម្មតាមច្បាប់ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ទទួលស្គាល់នូវគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិក្នុងសន្តតិកម្ម ដូចនេះសន្តតិជនក៏មានសិទ្ធិក្នុងការសម្រេចចិត្តថានឹងទទួលយកឬបោះបង់ចំណែកសន្តតិកម្មរបស់ខ្លួន។ ដោយគោលការណ៍យល់ព្រមឬបោះបង់សន្តតិកម្មនេះ ត្រូវបានយកមកអនុវត្តដើម្បីធានានូវជីវភាពរបស់កូនចៅជំនាន់ក្រោយដែលបានផ្ដល់អាទិភាពទៅឱ្យសន្តតិជនក្នុងការពិចារណាក្នុងករណីដែលកាតព្វកិច្ចមានច្រើនជាងសិទ្ធិ និងផលប្រយោជន៍ដែលទទួលបាន។

សន្តតិជនមានសិទ្ធិក្នុងការធ្វើការយល់ព្រម ឬ បោះបង់សន្តតិកម្មទាំងស្រុង ឬ ដោយមានកម្រិតក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលបានដឹងថាសន្តតិកម្មចំពោះខ្លួនបានចាប់ផ្ដើម។[40] រយៈពេលនេះអាចពន្យារបានតាមរយៈការដាក់ពាក្យសុំទៅតុលាការ ដើម្បីទុកលទ្ធភាពឱ្យសន្តតិជនធ្វើការស្រាវជ្រាវមត៌ក និងកាតព្វកិច្ចនៅមុនពេលដែលសន្តតិជនធ្វើការបង្ហាញឆន្ទៈក្នុងការយល់ព្រម ឬ បោះបង់ចំណែកសន្តតិកម្មរបស់ខ្លួន។ តុលាការដែលទទួលបានពាក្យសុំនេះត្រូវធ្វើការកំណត់រយៈពេលដែលត្រូវពន្យារនេះដោយវិនិច្ឆ័យទៅតាមចំនួន ឬគុណភាពនៃមត៌ក ឬ កាតព្វកិច្ចដែលទទួលបានដោយសន្តតិកម្មជាអាទិ៍។

ម្យ៉ាងវិញទៀតជាគោលការណ៍ការយល់ព្រម ឬការបោះបង់សន្តតិកម្មមិនអាចលុបចោលបានឡើយដោយហេតុថាការបោះបង់ឬការយល់ព្រមមានឥទ្ធិពលយ៉ាងខ្លាំងលើផលប្រយោជន៍របស់បុគ្គលពាក់ព័ន្ធដូចជាសន្តតិជន ឬ ម្ចាស់បំណុលរបស់មតកជនជាអាទិ៍ លើកលែងតែមានអត្ថិភាពនៃវិការៈក្នុងការបង្ហាញឆន្ទៈ។[41] ប្រសិនបើមានវិការៈនៃការបង្ហាញឆន្ទៈ សិទ្ធិនេះត្រូវធ្វើឡើងនៅក្នុងអំឡុងពេល ០៦ (ប្រាំមួយ) ខែ គិតចាប់ពី ពេលដែលអាចផ្ដល់សច្ចានុមតិ ឬ នៅក្នុងអំឡុងពេល ០៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលចាប់ផ្ដើមសន្តតិកម្មតាម រយៈការដាក់ពាក្យសុំទៅតុលាការ។[42] ក្នុងករណីសន្តតិជនមិនទាន់បានយល់ព្រម ឬ បោះបង់សន្តតិកម្ម ឬ អ្នកទទួលបន្តនៃសន្តតិកម្មមិនទាន់មានភាពច្បាស់លាស់ ប្រសិនបើម្ចាស់បំណុលរបស់មតកជនមានឆន្ទៈធ្វើបណ្ដឹង នោះគេត្រូវថាត់តាំងអ្នក

---

[39] មាត្រា១២៣៨(២) នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[40] មាត្រា១២៤៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[41] មាត្រា១២៥២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[42] មាត្រា១២៥២ កថាខណ្ឌទី២,៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

គ្រប់គ្រងមត៌កជាបណ្តោះអាសន្នសិនទើបអាចចាប់ផ្តើមសកម្មភាពបណ្តឹងបានចំពោះអ្នកគ្រប់គ្រងនោះ។ ករណីមតកជនបានទទួលមរណភាពស្របពេលមានបណ្តឹងកំពុងចាត់ការនោះនីតិវិធីបណ្តឹងត្រូវផ្អាករហូតដល់សន្តតិជនយល់ព្រមទទួលសន្តតិកម្មបន្ត ឬ ម្ចាស់បំណុលនៃមតកជននោះអាចទាមទារឱ្យមានអ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្នសិន ប្រសិនបើចង់ឱ្យនីតិវិធីបណ្តឹងនោះមានភាពឆាប់រហ័ស។

## ៤.១. ការយល់ព្រមទទួលសន្តតិកម្ម

ការយល់ព្រមទទួលបន្តនូវសន្តតិកម្មគឺ ជាការយល់ព្រមទទួលបន្តនូវសិទ្ធិនិងកាតព្វកិច្ចបន្តពីមតកជនក្នុងករណីសន្តតិជនបានយល់ព្រមទាំងស្រុង គឺសន្តតិជនត្រូវទទួលបន្តដោយគ្មានកម្រិតនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជននោះទេ។ ការយល់ព្រមទទួលសន្តតិកម្មបែងចែកជា២គឺការយល់ព្រមទាំងស្រុងនិងការយល់ព្រមមាកម្រិត។

### ៤.១.១. ការយល់ព្រមទាំងស្រុង

ការយល់ព្រមទាំងស្រុង មានន័យថាសន្តតិជនត្រូវទទួលបន្តដោយគ្មានកម្រិតនូវសិទ្ធិ និង កាតព្វកិច្ចរបស់មតកជន[43] ដោយករណីយល់ព្រមទាំងស្រុងតម្រូវឱ្យសន្តតិជនបង្ហាញឆន្ទៈថាយល់ព្រមទទួលយកគឺគ្រប់គ្រាន់ហើយ ដោយមិនចាំបាច់ដាក់ពាក្យសុំទៅតុលាការនោះទេ។ ចំពោះ ការយល់ព្រមមានកម្រិត និងការបោះបង់ចោលសន្តតិកម្ម គឺតម្រូវឱ្យមានការដាក់ពាក្យសុំទៅតុលាការ។

ប្រសិនបើសន្តតិជនបានធ្វើនូវសកម្មភាពណាមួយដែលមានកំណត់ក្នុងសកម្មភាពខាងក្រោមនេះ គឺត្រូវចាត់ទុកថាសន្តតិជនបានយល់ព្រមទាំងស្រុង៖

- សន្តតិជនបានចាត់ចែងមត៌កនោះទាំងអស់ឬមួយភាគ។ប៉ុន្តែលើកលែងចំពោះសកម្មភាពរក្សា និងសកម្មភាព ត្រឹមតែជាការគ្រប់គ្រង។
- សន្តតិជនមិនបានយល់ព្រមដោយមានកម្រិត ឬ បោះបង់ នៅក្នុងអំឡុងពេល ០៣ (បី) ខែ គិត ចាប់ពីថ្ងៃដែលបានដឹងថាសន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម។ លើកលែងតែសន្តតិជនបានដាក់ពាក្យសុំពន្យាពេលនេះទៅតុលាការ។
- ទោះបីជាសន្តតិជនបានយល់ព្រមដោយមានកម្រិត ឬ បោះបង់ក៏ដោយ បើសន្តតិជនបានលាក់មត៌កទាំងអស់ ឬ មួយភាគ ឬ បានប្រើប្រាស់មត៌កនោះដើម្បីខ្លួន។ លើកលែងតែនៅពេលក្រោយដែលជន ដែលបានក្លាយជាសន្តតិជនដោយសារការបោះបង់របស់សន្តតិជនលំដាប់មុនបានយល់ព្រម។[44]

### ៤.១.២. ការយល់ព្រមមានកម្រិត

ការយល់ព្រមដោយមានកម្រិត គឺជាករណីដែលសន្តតិជនយល់ព្រមដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និងអច្ច័យទានរបស់មតកជនបានត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្មតែប៉ុណ្ណោះ។[45] ក្នុងន័យនេះគឺសន្តតិជនត្រូវក្លាយទៅជាកូនបំណុល ដោយទទួលបន្ទុកនូវសន្តតិកម្មនៃកាតព្វកិច្ចទាំងអស់របស់

---

[43] មាត្រា១២៥៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[44] មាត្រា១២៥៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[45] មាត្រា១២៥៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

មតកជន ប៉ុន្តែសន្តតិជនអាចកម្រិតការទទួលខុសត្រូវបាន ឱ្យនៅត្រឹមកម្រិតនៃមត៌កដែលខ្លួនទទួល លើកលែងតែសន្តតិជនយល់ព្រមសងកាតព្វកិច្ចដោយស្មគ្រ័ចិត្ត។ នៅក្នុងករណីដែលមានសហសន្តតិជន នោះការយល់ព្រមដោយមានកម្រិតត្រូវធ្វើឡើងរួមគ្នា ហើយចាំបាច់ត្រូវមាននីតិវិធីជម្រះបញ្ជីដើម្បីឱ្យមានសមភាពក្នុងការសងចំពោះម្ចាស់បំណុលរបស់មតកជន។[46] សហសន្តតិជនត្រូវឯកភាពគ្នាក្នុងការសងនោះ ដោយហេតុថាប្រសិនបើមានតែសន្តតិជនមួយចំនួនបានយល់ព្រម ហើយបានអះអាងនូវចំណែកមត៌ក នោះការជម្រះបញ្ជីនូវមត៌កទាំងអស់នឹងមិនអាចធ្វើទៅរួច។ ក្នុងករណីដែលមានសន្តតិជនណាមួយបោះបង់នូវសន្តតិកម្មនោះគេត្រូវការតែយល់ព្រមពីសន្តតិជនដែលនៅសល់ប៉ុណ្ណោះ ពីព្រោះបុគ្គលដែលបានបោះបង់សន្តតិកម្មត្រូវចាត់ទុកថាមិនមែនជាសន្តតិជនតាំងពីដំបូង។

ដើម្បីធ្វើការយល់ព្រមដោយមានកម្រិតចំពោះសន្តតិកម្មដែលកើតមានឡើងចំពោះខ្លួន (សន្តតិជន) ត្រូវធ្វើតាមរបៀបដែលមានកំណត់ដូចខាងក្រោម៖

- សន្តតិជនត្រូវដាក់ពាក្យសុំទៅតុលាការក្នុងអំឡុងពេល ០៣(បី)ខែគិតចាប់ពីថ្ងៃដែលដឹងថាសន្តតិកម្មចាប់ផ្តើមចំពោះខ្លួន។ សន្តតិជនត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃមត៌ក ដោយបញ្ជាក់អំពីមត៌កសកម្ម និងមត៌កអកម្មដែលឲសន្តតិជនបានទទួល នាពេលចាប់ផ្តើមសន្តតិកម្ម ក្នុងកម្រិតលទ្ធភាពដែលខ្លួនបានដឹង។ ករណីមិនបានបញ្ជាក់ឱ្យច្បាស់លាស់ដោយចេតនាត្រូវចាត់ទុកថា "យល់ព្រមទាំងស្រុង"។[47]

ចំពោះអានុភាពនៃការយល់ព្រមដោយកម្រិត គឺធ្វើឱ្យម្ចាស់បំណុលរបស់មតកជនមិនអាចទាមទារឱ្យសន្តតិជនទទួលខុសត្រូវចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជនដែលមានបានឡើយ។[48] ទោះបីជាដូច្នេះក៏ដោយ តាមគោលការណ៍មត៌កត្រូវធ្លាក់ទៅលើសន្តតិជនប៉ុន្តែជាលក្ខណៈសារធាតុទ្រព្យសម្បត្តិជាមត៌កត្រូវធ្វើការជម្រះបញ្ជីផ្សេងៗពីទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជន ហេតុនេះសិទ្ធិលើបំណុល និងកាតព្វកិច្ចរបស់សន្តតិជននិងមតកជនមិនអាចរលត់ដោយព្យាកុលភាពនោះទេ។[49]

## ៤.២. ការបោះបង់សន្តតិកម្ម

សន្តតិជនអាចធ្វើការបោះបង់សន្តតិកម្មបានក្នុងអំឡុងពេល ៣ ខែគិតចាប់ពីបានដឹងថាសន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម។[50] ការផ្តល់សិទ្ធិឱ្យសន្តតិជនអាចធ្វើការបោះបង់សន្តតិកម្មបានគឺដើម្បីការពារសន្តតិជនពីការក្ស័យធនក្នុងករណីមតកជនមានជាប់កាតព្វកិច្ចយ៉ាងធ្ងន់ធ្ងរដែលសន្តតិជនមិនអាចរ៉ាប់រងបានឬការរ៉ាប់រងនោះអាចប៉ះពាល់ដល់ជីវភាពរស់នៅរបស់សន្តតិជននោះ ឬជួយរំដោះសន្តតិជនពីកាតព្វកិច្ចមួយចំនួនដែលសន្តតិជនមិនចង់បាន។ សន្តតិជនដែលមានបំណងចង់ធ្វើការបោះបង់ចោលសន្តតិកម្មគឺត្រូវធ្វើការដាក់ពាក្យសុំទៅកាន់តុលាការមានសមត្ថកិច្ច ដែលជាទីកន្លែងចាប់ផ្តើមសន្តតិកម្ម (លំនៅដ្ឋានរបស់មតកជននាពេលទទួលមរណភាព)

---

[46] មាត្រា១២៥៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[47] មាត្រា១២៥៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[48] មាត្រា១២៥៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[49] មាត្រា១២៥៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[50] មាត្រា១២៤៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

អំឡុងពេល៣ខែគិតចាប់ពីបានដឹងសន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម ដោយបញ្ជាក់ពីហេតុផលដែលចង់បោះបង់សន្តតិកម្មនោះ។ នៅក្នុងអំឡុងពេលនោះសន្តតិជនអាចធ្វើកាស្រាវជ្រាវអំពីសិទ្ធិនិងកាតព្វកិច្ចថាទទួលបានកម្រិតណា ឬត្រូវបោះបង់ទាំងស្រុង។

ការបោះបង់សន្តតិកម្មរបស់សន្តតិជន មានអនុភាពនៅពេលតុលាការចេញដីការសម្រេចអនុញ្ញាតឱ្យសន្តតិជននោះអាចធ្វើការបោះបង់សន្តតិកម្មបាន។ យោងតាមមាត្រា១២៦១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧បានចែងថា " បុគ្គលដែលបានបោះបង់សន្តតិកម្មត្រូវចាត់ទុកថាបុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដើមដំបូងមក"  មាត្រានេះមានន័យថាការបោះបង់សន្តតិកម្មនេះមានភាពប្រតិសកម្មដែលអាចចាត់ទុកបុគ្គលដែលបោះបង់សន្តតិកម្មនោះថាមិនមែនជាសន្តតិជន តាំងពីថ្ងៃដែលមតកជនបានទទួលមរណៈភាពដែលជាថ្ងៃបើកសន្តតិកម្មនោះ។ នៅពេលសន្តតិជនម្នាក់បានធ្វើការបោះបង់សន្តតិកម្ម សន្តតិជនដទៃទៀតជាអ្នកទទួលយកចំណែកដែលបានបោះបង់នោះ។ ក្នុងករណីសហសន្តតិជនក្នុងលំដាប់តែមួយធ្វើការបោះបង់សន្តតិកម្មទាំងអស់គ្នានោះសន្តតិជនដែលមានលំដាប់បន្ទាប់ជាអ្នកទទួលសន្តតិកម្មនោះ។ ការបោះបង់ចោលសន្តតិកម្មមិនអាចធ្វើការលុបចោលនោះទេ ព្រោះថាអាចធ្វើឱ្យមានការប៉ះពាល់ប្រយោជន៍ទៅដល់សន្តតិជនដែលមានលំដាប់បន្ទាប់។ ប៉ុន្តែអាចធ្វើការទាមទារឱ្យលុបចោលការបោះបង់បានក្នុងករណីដែលការបង្ហាញឆន្ទៈមានវិការៈ ដូចជាការភាន់ច្រឡំ ការគម្រាមកំហែងជាដើម។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងបកស្រាយប្រធានបទស្ដីពី "**សន្តតិកម្មតាមច្បាប់**" រួចមក យើងអាចធ្វើការសន្និដ្ឋានបានថា របបសន្តតិកម្ម គឺជារបបគតិយុត្តិមួយដែលក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បញ្ញត្តិឡើងដើម្បីគោរពទោលើញាតិភាពរបស់មតកជន ដែលញាតិលោហិតខ្សែផ្ទាល់មានសិទ្ធិ និងកាតព្វកិច្ចបន្តពីមតកេជន ក្នុងឋានៈជាសាច់សាលោហិតពីធម្មជាតិ។ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ ដែលយើងបានសិក្សាខាងដើមនេះ បានបញ្ញត្តិយ៉ាងលម្អិតចំពោះសន្តតិកម្មតាមច្បាប់ ធ្វើឱ្យមានការអនុវត្តត្រឹមត្រូវទាក់ទងទៅនឹងផ្នែកនេះ មួយវិញទៀតសន្តតិជនក៏អាចបង្ហាញនូវឆន្ទៈ ថាយល់ព្រមទទួល ឬ បោះបង់នូវការស្នងសន្តតិកម្មនេះបាន ប្រសិនបើកាតព្វកិច្ចដែលត្រូវទទួល ឬហៅម៉្យាងទៀតថាទ្រព្យអកម្មគឺធ្ងន់ធ្ងរពេក។

ប្រសិនបើយើងពិនិត្យមើលទោលើភាពជាក់ស្ដែងដែលតែងតែអនុវត្តនៅក្នុងសង្គមវិញ ប្រជាជនភាគច្រើនមិនស្គាល់ពីសន្តតិកម្មតាមច្បាប់ និងបានអនុវត្តឱ្យបានទូលំទូលាយនោះទេ ដោយមនុស្សភាគច្រើនមិនបានយល់ដឹងពីអត្ថន័យនៃពាក្យសន្តតិកម្មនេះ ប៉ុន្តែយើងឃើញថានៅក្នុងការរស់នៅកន្លងមក មានដូចជា ការប្រគល់ឱ្យនូវទ្រព្យណាមួយពីមតកជនទៅទាយាទរបស់ខ្លួន ដែលជាការអនុវត្តទូទៅតាមទំនៀមទម្លាប់។ កង្វះការយល់ដឹងផ្នែកច្បាប់នេះហើយ ដែលធ្វើឱ្យប្រជាពលរដ្ឋមួយចំនួន មានទំនាស់ក្នុងការចែកមត៌ករបស់មតកជន ហើយឈានដល់ការមានជា ទំនាស់គ្រួសារថែមទៀត ដោយសារការបែងចែកមត៌កគ្មានភាពស្មើគ្នា ឬសន្តតិជនម្នាក់ៗចង់បានចំណែកច្រើនរៀងៗខ្លួន ហើយអាចកើតមានការប្ដឹងគ្នាដល់តុលាការទៀតផង។ អាស្រ័យហេតុនេះ សន្តតិកម្មតាមច្បាប់នេះបានដើរតួនាទីយ៉ាងមានប្រសិទ្ធភាពក្នុងការការពារផលប្រយោជន៍របស់សន្តតិជន។

ដូចនេះហើយទើបការសិក្សាពី "**សន្តតិកម្មតាមច្បាប់**" មានសារៈសំខាន់ណាស់ ព្រោះវាជាភាពចាំបាច់ក្នុងការអនុវត្តជាក់ស្ដែងក្នុងជីវភាពសង្គម។ ប្រសិនបើប្រជាពលរដ្ឋបានទទួលនូវចំណេះដឹងទាក់ទងនឹងសន្តតិកម្ម នោះវិវាទ ការប៉ះពាល់សិទ្ធិ និងផលប្រយោជន៍ផ្សេងៗត្រូវបានកាត់បន្ថយផងដែរ ដែលជាការរួមចំណែកក្នុងលើកកម្ពស់ការអនុវត្តស្របតាមច្បាប់ប្រកបដោយប្រសិទ្ធិភាព និរន្តរភាព តម្លាភាពលើប្រព័ន្ធច្បាប់នៅប្រទេសកម្ពុជា។

យ៉ាងណាមិញ ចំណុចខ្វះខាតគឺនៅតែមានដោយសារការវិវត្តនៃបរិបទសង្គម ដែលទាមទារឱ្យមាននូវការវិវត្តនៃបញ្ញត្តិនៃច្បាប់ទៅតាមស្ថានភាពសង្គមផងដែរ។ ការតាក់តែងច្បាប់នីមួយៗមិនអាចបំពេញតម្រូវការ និងសមស្របតាមបរិបទនៃការអនុវត្តឱ្យបានល្អឥតខ្ចោះនោះទេ ទោះបីជាការតាក់តែងនោះមានភាពល្អយ៉ាងណាក្ដីនាពេលតាក់តែងនោះ ក៏មិនមានន័យថា ការអនុវត្តរបស់វាមានប្រសិទ្ធភាពគ្រប់ពេលវេលា និងកាលៈទេសៈ នោះដែរ ដែលនេះហើយទាមទារឱ្យអ្នកតាក់តែងច្បាប់ធ្វើឱ្យការតាក់តែងច្បាប់ដែលមានភាពបត់បែនទៅតាមការអភិវឌ្ឍន៍ដ៏ជឿនលឿននៃសង្គមផងដែរ។

# អនុសាសន៍

បន្ទាប់ពីការសិក្សាស្រាវជ្រាវទៅលើប្រធានបទ "សន្តតិកម្មតាមច្បាប់" ខាងលើនេះរួចមក យើងខ្ញុំពិតជាទទួលបាននូវចំណេះដឹងបន្ថែមទៅលើប្រធានបទខាងលើ ព្រមទាំងទទួលបាននូវបទពិសោធន៍ក្នុងការធ្វើការស្រាវជ្រាវគតិយុត្ត ក៏ដូចជាចំណេះដឹងក្នុងការសរសេរអត្ថបទគតិយុត្តិជាច្រើនដែលជាផលប្រយោជន៍សម្រាប់យើងខ្ញុំទៅថ្ងៃខាងមុខ។ ចំពោះគោលបំណងនៃការសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើនេះ គឺដោយសារតែបន្ទាប់ពីយើងខ្ញុំបានសិក្សាត្រួសៗទៅលើប្រធានបទសន្តតិកម្មនៅក្នុងថ្នាក់រៀន យើងខ្ញុំក៏មានបំណងក្នុងការស្វែងយល់បន្ថែមទៅលើប្រធានបទនេះ ហើយយើងខ្ញុំក៏ចង់ចែករំលែកចំណេះដឹងនេះទៅកាន់សិស្សានុសិស្ស ដែលមានបំណងចង់សិក្សាស្វែងយល់អំពីរបបសន្តតិកម្មតាមច្បាប់ គោលការណ៍នៃសន្តតិកម្មតាមច្បាប់ក៏ដូចជារូបមន្តក្នុងការបែងចែកចំណែកមត៌កផ្សេងៗផងដែរ។

ក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវ យើងខ្ញុំសូមចូលរួមចំណែកក្នុងការបញ្ចេញមតិយោបល់មួយចំនួន ដើម្បីធ្វើឱ្យមានភាពប្រសើរឡើងនូវរបបសន្តតិកម្មនៅប្រទេសកម្ពុជាយើង។ ដោយយើងខ្ញុំឃើញថាប្រជាជននៅក្នុងប្រទេសកម្ពុជាយើង ធ្លាប់ដឹងពីប្រវត្តនៃក្នុងការចែកទ្រព្យពីឪពុកម្តាយ ទៅកូនចៅ តៗគ្នាដែលអាចនិយាយបានថាជាទំនៀមទម្លាប់មួយដែលមនុស្សភាគច្រើន យល់ឃើញថាមិនចាំបាច់ក្នុងការមានច្បាប់មកកំណត់នោះឡើយ តែយ៉ាងណាមិញក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវហើយ យើងខ្ញុំយល់ឃើញថាបញ្ញត្តិនៃច្បាប់នេះគឺមានសារៈសំខាន់ណាស់ ក្នុងការគ្រប់គ្រងទៅលើរបបបែងចែកមត៌កនេះ ដោយបញ្ញត្តិនៃច្បាប់មានការធានាទៅលើចំណែកមត៌ករបស់សន្តតិជនដែលស្របច្បាប់ ក៏ដូចជាកំណត់ថាតើជនណាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការក្លាយទៅជាសន្តតិជនផងដែរ។ មិនតែប៉ុណ្ណោះបញ្ញត្តិនៃច្បាប់ក៏ធានាទៅលើសមភាពនៃចំណែករបស់សន្តតិជននីមួយៗ និងឱ្យលើសឬខ្វះឡើយ។ យើងខ្ញុំសង្ឃឹមថាអ្នកដែលអនុវត្តច្បាប់អាចធ្វើការផ្សព្វផ្សាយ ក៏ដូចជាពន្យល់ពីបញ្ញត្តិនៃច្បាប់ ក៏ដូចជាការផ្តល់នូវចំណេះដឹងទាក់ទងនឹងរបបសន្តតិកម្មតាមច្បាប់នេះទៅកាន់ប្រជាជនកម្ពុជាយើង ឱ្យកាន់តែទូលំទូលាយ និងនាំមកនូវការអនុវត្តច្បាប់ដែលមានប្រសិទ្ធភាព។

ថ្វីត្បិតតែអនុសាសន៍ខាងលើរបស់យើងខ្ញុំមិនទាន់គ្រប់គ្រាន់ និងស៊ីជម្រៅក៏ដោយ តែយើងខ្ញុំសង្ឃឹមថាវាអាចជាកត្តាមួយជួយជម្រុញដល់ការចូលរួមអភិវឌ្ឍ និងកាត់បន្ថយនូវវិវាទផ្សេងៗរវាងញាតិទាក់ទងទៅនឹងការបែងចែកមត៌ក រួមទាំងរួមចំណែកក្នុងការធ្វើឱ្យមានភាពសុខសាន្តសុខដុមរមនានៅក្នុងរង្វង់គ្រួសារ និងសង្គមជាតិផងដែរ។

# ឯកសារយោង

# ឯកសារយោង

## I. បទដ្ឋានគតិយុត្តិ

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

ច្បាប់ស្ដីពីការផ្ដល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១០/០០៦ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០

ច្បាប់ស្ដីពីអគ្រានុកូលដ្ឋាន ស្ថិតិអគ្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣

ច្បាប់ស្ដីពីអន្តោប្រវេសន៍ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០៥នស៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤

សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦: គន្លឹ៨-៩ រៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី ឆ្នាំ២០១០។

អនុក្រឹត្យលេខ១០៣ អនក្រ.បក ស្ដីពីអគ្រានុកូលដ្ឋាន ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រមរដ្ឋប្បវេណី

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

## ឆ្នាំ២០០៧

**មាត្រា ៤១. លក្ខខណ្ឌដើម្បីធ្វើការប្រកាសអំពីការបាត់ខ្លួន**

១- ប្រសិនបើពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាព ក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ តុលាការអាចប្រកាសបានថា បុគ្គលនោះ បានបាត់ខ្លួន តាមពាក្យសុំរបស់សហព័ទ្ធ អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី អ្នកទទួល ប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុកម្ដាយ ឬ អ្នក ផ្សេងទៀតដែលមានផលប្រយោជន៍សំខាន់តាមផ្លូវច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណី បុគ្គលដែលចូលទៅតំបន់ដែលមានសង្គ្រាម បុគ្គលដែលមានវត្តមាននៅក្នុងនាវាដែល បានលិច ឬ បុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងទៀតដែលអាចនាំឱ្យទទួល មរណភាព ហើយពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាព ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក្រោយពីចប់សង្គ្រាម ក្រោយពីនាវាបានលិច ឬ ក្រោយ ពីព្រោះថ្នាក់ផ្សេងទៀតនោះ បានកន្លងផុតទៅ ។

**មាត្រា ៤៥.ការចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា**

ក្នុងចំណោមបុគ្គលដែលបានទទួលមរណភាពជាច្រើននាក់ ប្រសិនបើមិនច្បាស់លាស់ថា មានបុគ្គលណាម្នាក់នៅរស់ ក្រោយពេលបុគ្គលផ្សេងទៀតបានទទួលមរណភាពទេ បុគ្គលទាំងនោះត្រូវបានចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា។

**មាត្រា ១០១៤.ការបញ្ចប់នូវញាតិភាពជាមួយនឹងឪពុកម្ដាយបង្កើត**

ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុក ម្ដាយបង្កើតនោះ ត្រូវបញ្ចប់ ដោយសុំកូនពេញលេញ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះញាតិភាពជាមួយនឹងឪពុកម្ដាយម្ខាងទៀត និង ញាតិលោហិតរបស់ ឪពុកម្ដាយម្ខាងទៀតនោះ ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ២ នៃមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្ដីប្រពន្ធ) នៃក្រមនេះ ។

**មាត្រា ១០២៦.អានុភាពនៃសុំកូនធម្មតា ចំពោះបុត្តភាព**

១-ទោះបីជាមានការបង្កើតសុំកូនធម្មតាក៏ដោយ ញាតិភាពរវាងកូនសុំ និង ឪពុក ម្ដាយបង្កើត ត្រូវបន្តអត្ថិភាព ហើយកូនសុំ និង ឪពុកម្ដាយបង្កើត មានសិទ្ធិធ្វើសន្តតិកម្មគ្នា ទៅវិញទៅមក ។

២-កូនសុំ និង ឪពុកម្ដាយបង្កើត មានសិទ្ធិទាមទារ និង ករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ។

**មាត្រា ១១៤៥.មូលហេតុនៃការចាប់ផ្ដើមធ្វើសន្តតិកម្ម**

១- សន្តតិកម្ម ត្រូវចាប់ផ្ដើមដោយមរណភាពរបស់មតកជន ។

២-សន្តតិកម្ម ត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ឬ ដោយផ្អែកតាមឆន្ទៈ របស់មតកជន ។ សន្តតិកម្មដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ហៅថា សន្តតិកម្មតាមច្បាប់ សន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជន ហៅថា សន្តតិកម្មមានបណ្ដាំ ។

**មាត្រា ១១៤៦.ទីកន្លែងចាប់ផ្ដើមសន្តតិកម្ម**

សន្តតិកម្ម ត្រូវចាប់ផ្ដើមនៅលំនៅឋានរបស់មតកជន នាពេលទទួលមរណភាព ។

**មាត្រា ១១៥៦.សន្តតិជនដែលមានលំដាប់ទី ១**

១-កូនរបស់មតកជន ត្រូវក្លាយជាសន្តតិជនដែលមានលំដាប់ទី១។

២-កូនរបស់មតកជន ទោះបីជាកូនបង្កើតក្ដី ឬ កូនសុំក្ដី ត្រូវមានចំណែកមត៌កស្មើៗគ្នា ។

**មាត្រា ១១៥៧.សន្តតិកម្មជំនួស**

១- បើកូនរបស់មតកជន បានទទួលមរណភាព នៅមុនពេលចាប់ផ្ដើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) ខាងលើនេះ ឬ ដោយការផ្ដាច់មត៌ក កូនរបស់ បុគ្គលនោះ ត្រូវក្លាយទៅជាសន្តតិជនជំនួស ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្ត ឡើយ ចំពោះបុគ្គលដែលមិនមែនជាបច្ឆាញាតិផ្ទាល់របស់មតកជន

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តជាបន្តបន្ទាប់ ចំពោះករណីដែលមានមូលហេតុដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះ ចំពោះអ្នក ទទួលសន្តតិកម្មជំនួស ។

**មាត្រា ១១៥៨.ចំណែកមត៌ក ក្នុងករណីនៃសន្តតិកម្មជំនួស**

ចំណែកមតិក របស់បច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន ដោយយោងតាម បញ្ញត្តិនៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) ខាងលើនេះ ត្រូវដូចគ្នានឹងចំណែកមតិក ដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់នោះត្រូវទទួលបាន ។ ប្រសិនបើបច្ឆាញាតិផ្ទាល់ មានចំនួនច្រើននាក់ ចំណែកមតិកដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់រៀងៗខ្លួននោះ ត្រូវទទួលបាន ត្រូវបែងចែកស្មើៗគ្នា រវាងបច្ឆាញាតិទាំងឡាយនោះ ។

**មាត្រា ១១៥៩.. សន្តតិជនដែលមានលំដាប់ទី ២**

១-បើមតកជនពុំមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ បុព្វញាតិផ្ទាល់ របស់មតកជននោះ ត្រូវក្លាយជាសន្តតិជន ។ ប៉ុន្តែ រវាងបុគ្គលដែលមានថ្នាក់ញាតិខុសគ្នាត្រូវយកបុព្វញាតិដែលនៅជិតជាង ជាមុន ។

២-ប្រសិនបើបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន មានចំនួនច្រើននាក់បុព្វញាតិផ្ទាល់នីមួយៗត្រូវទទួលចំណែកមតិកស្មើៗគ្នា ។

**មាត្រា ១១៥១.ការផ្តាច់មតិកពីសន្តតិជន**

១-មតកជន កាលនៅរស់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យផ្តាច់មតិកពីជនដែលត្រូវ បានសន្មតថាជាសន្តតិជននោះ មិនឱ្យទទួលសន្តតិកម្មបាន បើជនដែលត្រូវបានសន្មតថាជា សន្តតិជនដែលមានភាគបម្រុង បានប្រព្រឹត្តនូវសកម្មភាពដែលបានកំណត់ខាងក្រោមនេះ:

ក-បើបានធ្វើបាបចំពោះមតកជន ។

ខ-បើបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ ។

គ-បើអាចមកមើលថែទាំមតកជននៅពេលដែលមានជម្ងឺ ប៉ុន្តែមិនមកថែទាំ ។

ឃ-បើត្រូវបានទទួលសាលក្រម ឬ សាលដីកាផ្តន្ទាទោសឱ្យជាប់ពន្ធនាគារមួយជីវិត ។

ង-បើបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឱ្យកត់សំគាល់ ជាអាទិ៍ ។

មតកជន ក៏អាចបង្ហាញឆន្ទៈអំពីការផ្តាច់មតិកនេះ តាមមតកសាសន៍បានដែរ ។

២-ជនដែលត្រូវបានសន្មតថាជាសន្តតិជនដែលបានទទួលការទាមទារផ្តាច់មតិក នេះ អាចធ្វើវិវាទអំពីអត្ថិភាព ឬ នត្ថិភាព នៃមូលហេតុនៃការផ្តាច់បដឹកនេះ នៅក្នុងការ សម្រេចសេចក្តីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បាន ។

**មាត្រា ១១៦០.សន្តតិជនដែលមានលីដាប់ទី ៣**

១-បើមតកជនពុំមានទាំងបច្ឆាញាតិផ្ទាល់ ទាំងបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ បងប្អូនបង្កើតរបស់មតកជននោះ ត្រូវក្លាយជាសន្តតិជន ។

២-បើបងប្អូនបង្កើតបានចំនួនច្រើននាក់ បងប្អូនបង្កើតម្នាក់ៗត្រូវបានចំណែកមតិកភាគស្មើៗគ្នា ។ ប៉ុន្តែចំណែកមតិករបស់បងប្អូនបង្កើតដែលមានឪពុក ឬ ម្តាយតែម្ខាងដូចគ្នាត្រូវមាន ១ ភាគ ២ (មួយភាគពីរ) នៃចំណែកមតិករបស់បងប្អូនដែលមាន ឪពុក និង ម្តាយទាំងសងខាងដូចគ្នា ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) និង បញ្ញត្តិនៃ មាត្រា ១១៥៨ (ចំណែកមតិក ក្នុងករណីនៃសន្តតិកម្មជំនួស) ខាងលើនេះ ត្រូវយកមក អនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបងប្អូនបង្កើតរបស់មតកជនដែលត្រូវក្លាយជា សន្តតិជន យោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ បានទទួលមរណភាពនៅមុនពេលចាប់ផ្តើមសន្តតិកម្ម ។

**មាត្រា ១១៦១.សន្តតិកម្មរបស់សហព័ទ្ធ**

១-សហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច ។

២-នៅក្នុងករណីដែលសហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជន បើមាន បុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវជាសន្តតិជនដែរ ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) ខាងលើនេះ សហព័ទ្ធនោះត្រូវមានលំដាប់ស្មើគ្នានឹងបុគ្គលនោះ ។

**មាត្រា ១១៦២.ចំណែកមតិក ក្នុងករណីដែលមានសហព័ន្ធ**

ក្នុងករណីដែលសហព័ទ្ធរបស់មតកជន និង បុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវ ក្លាយជាសន្តតិជន ចំណែកមតិករបស់សន្តតិជន នឹងត្រូវមានតាមកំណត់ដូចខាងក្រោម

ក-បើសហព័ន្ធ និង បច្ឆាញាតិផ្ទាល់របស់មតកជននោះ ជាសន្តតិជន សហព័ទ្ធ និង កូននីមួយៗ របស់មតកជននោះ នឹងត្រូវទទួលចំណែកបតិកស្មើគ្នា ។

ខ-បើសហព័ន្ធ និង ឪពុក ម្ដាយរបស់មតកជន ជាសន្តតិជន ចំណែកមតិករបស់សហព័ន្ធ ត្រូវជា ១ ភាគ ៣ (មួយភាគបី) ឯចំណែកមតិករបស់ឪពុក ម្ដាយ ត្រូវជា ២ ភាគ ៣ (ពីរភាគបី) ។ ប៉ុន្តែ បើឪពុក ឬ ម្ដាយ របស់មតកជនតែម្នាក់នៅរស់ ឪពុក ម្ដាយនោះ និង សហព័ន្ធ ត្រូវបានចំណែកមតិកស្មើគ្នា ។

គ-បើសហព័ទ្ធ និង បុព្វញាតិផ្ទាល់ក្រៅពីឪពុក ម្ដាយរបស់មតកជន ឬ បងប្អូន បង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសបុគ្គលទាំងនោះ ជាសន្តតិជន ចំណែក មតិករបស់សហព័ទ្ធ ត្រូវជា ១ ភាគ ២ (មួយភាគពីរ) ឯចំណែកមតិករបស់បុព្វញាតិផ្ទាល់ ក្រៅពីឪពុក ម្ដាយរបស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្ម ជំនួសនោះ ត្រូវជា ១ ភាគ ២ (មួយភាគពីរ) ។

**មាត្រា ១១៦៣.ចំណែកមតិករបស់អ្នកទទួលផលប្រយោជន៍ពិសេស**

១-នៅក្នុងចំណោមសហសន្តតិជនទាំងអស់ បើមានបុគ្គលណាដែលបានទទួល ប្រទានកម្ម នៅក្នុងគឺកាសអាពាហ៍ពិពាហ៍ ឬ ហេតុការណ៍ផ្សេងទៀត ឬ ដើម្បីមូលធននៃ ជីវភាពរស់នៅ ឬ ដែលបានទទួលអច្ច័យទានពីមតកជននោះ តម្លៃសរុបនៃមតិកដែល មតកជនមាននៅពេលចាប់ផ្ដើមសន្តតិកម្ម ដោយបូកបញ្ចូលនូវតម្លៃនៃប្រធានកម្ម ត្រូវបាន ចាត់ទុកថាជាមត៌ក ហើយចំនួនទឹកប្រាក់ដែលនៅសល់ ក្រោយពីដកតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាននោះ ចេញពីចំណែកមតិកដែលត្រូវបានគណនាតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) និង ផ្នែកទី ២ (សន្តតិកម្មរបស់សហព័ទ្ធ) គឺជាចំណែកមតិករបស់បុគ្គលនោះ ។

២-បើតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាន ស្មើគ្នានឹងតម្លៃនៃចំណែកមតិក ឬ លើស ពីតម្លៃនៃចំណែកមតិក សហសន្តតិជននោះពុំអាចទទួលយកចំណែកមតិកនោះបានឡើយ ។

**មាត្រា ១១៦៤.តម្លៃនៃប្រទានកម្ម**

បើបដិគ្គាហក បានចាត់ចែងទ្រព្យសម្បត្តិដែលខ្លួនទទួលដោយប្រធានកម្ម នៅមុន ពេលចាប់ផ្ដើមសន្តតិកម្ម ឬ បើទ្រព្យសម្បត្តិនោះត្រូវបានបាត់ ឬ វិនាស នៅមុនពេល ចាប់ផ្ដើមសន្តតិកម្ម តម្លៃនៃប្រទានកម្មដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែក មតិករបស់អ្នកទទួលផលប្រយោជន៍ពិសេស) ខាងលើនេះ ត្រូវកណនា ដោយកើតតម្លៃនៅ ពេលដែលបានចាត់ចែង ឬ នៅពេលបាត់បង់ ឬ វិនាសនោះ ។ ប្រសិនបើតម្លៃនៃ ប្រទានកម្មនោះត្រូវបានផ្លាស់ប្ដូរ ដោយសារលទ្ធផលដែលបដិគ្គាហក បានផ្លាស់ប្ដូរទ្រព្យ សម្បត្តិនោះមួយផ្នែក តម្លៃនៃប្រទានកម្មនោះ ត្រូវគណនាដោយចាត់ទុកថា មានស្ថានភាពដើម នៅពេលចាប់ផ្ដើមសន្តតិកម្ម ។ ការប្រាក់ និង ផលចំណេញ ដែលកើតចេញពី ប្រធានកម្ម ដែលសន្តតិជននោះបានទទួល ពុំត្រូវគណនាចូលក្នុងតម្លៃនោះឡើយ ។

**មាត្រា ១១៦៥. ករណីដែលតម្លៃទទួលផលប្រយោជន៍ពិសេសនោះ លើសពីតម្លៃនៃ ចំណែកមតិក**

១-ទោះបីជាតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាន ដែលសហសន្តតិជនបានទទួល មានចំនួនលើសពីតម្លៃនៃចំណែកមតិកក៏ដោយ សហសន្តតិជននោះ ពុំចាំបាច់បង្វិលមក វិញ នូវទ្រព្យសម្បត្តិដែលទាក់ទងនឹងប្រទានកម្ម ដើម្បីសហសន្តតិជនផ្សេងទៀតឡើយ លើកលែងតែត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ ចំណែកមតិក របស់សហសន្តតិជនផ្សេងទៀត ត្រូវបានចំនួនទឹកប្រាក់ តាមការគណនា ដោយយកមតិក ដែលមតកជនមាននៅពេលចាប់ផ្ដើមសន្តតិកម្ម ទៅបែងចែកតាមសមាមាត្រនៃចំណែក មតិករបស់សហ

សន្តតិជននីមួយៗ ដែលត្រូវបានកំណត់ដោយយោងតាមបញ្ញត្តិនៃកថា ខណ្ឌទី ១ មាត្រា ១១៦៣ (ចំណែកមតិករបស់អ្នកទទួលផលប្រយោជន៍ពិសេស) ខាងលើ។

**មាត្រា ១១៦៦.ភាគនៃវិភាគទាន**

១-ក្នុងចំណោមសហសន្តតិជនទាំងឡាយ បើមានបុគ្គលណាបានធ្វើវិភាគទាន ពិសេស ដើម្បីថែរក្សា ឬ បង្កើនទ្រព្យសម្បត្តិរបស់មតកជន ដោយការផ្តល់សេវកម្មលើ កិច្ចការរបស់មតកជន ឬ ដោយការផ្តល់តាវកាលិកលើទ្រព រការផ្តល់តាវកាលិកលើទ្រព្យសម្បត្តិ ឬ ដោយការថែទាំព្យាបាលមតកជន ឬ ដោយវិធីផ្សេងទៀត តម្លៃដែលដកភាគនៃវិភាគទានរបស់បុគ្គលនោះ ដែលបានកំណត់តាមការពិភាក្សារបស់សហសន្តតិជន ចេញពីតម្លៃមតិកដែលមតកជន មាននៅពេលចាប់ផ្តើមសន្តតិកម្ម ត្រូវចាត់ទុកថាជាបតិក ហើយចំនួនទឹកប្រាក់នៃភាគ នៅក្នុងសន្តតិកម្ម ដែលបានគណនាតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) និង (សន្តតិកម្មរបស់សហព័ទ្ធ) បូកនឹងភាគវិភាគទាន ត្រូវជាចំណែកមតិករបស់ជននោះ ។

២-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់ភាគនៃវិភាគមាន តាមពាក្យសុំរបស់បុគ្គលដែលបានធ្វើវិភាគទានដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នោះ ដោយពិចារណាទៅលើពេល វិធី និង កម្រិតនៃវិភាគមាននោះ ចំនួនទឹកប្រាក់នៃមតិក និង ស្ថានភាពទាំងអស់ផ្សេងទៀត ។

៣-ភាគនៃវិភាគទាន មិនអាចឱ្យលើសពីចំនួនទឹកប្រាក់ដែលបានដកចេញនូវតម្លៃ នៃវត្ថុយទាន និង តម្លៃនៃទ្រព្យសម្បត្តិ ដែលមតកជនបានកំណត់ថាជាចំណែកបតិក របស់សហសន្តតិជន ឬ ជាវិធីបែងចែកបតិក ពីចំនួនតម្លៃនៃបតិក ដែលមតកជនមាន នៅពេលចាប់ផ្តើមសន្តតិកម្មឡើយ ។

៤-ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាចធ្វើបានក្នុង ករណីដែលមានពាក្យសុំ ដោយយោងតាមកថាខណ្ឌទី ១ នៃមាត្រា ១២៧០ (ការបែងចែក ដោយតុលាការ) ឬ មានពាក្យបណ្តឹង ដោយយោងតាមមាត្រា ១២៧៤ (ការទាមទាររបស់ ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមតិក) ។

**មាត្រា ១២៣០.អ្នកមានសិទ្ធិលើភាគបម្រុង**

១-បច្ឆាញាតិផ្ទាល់ ឬ ឪពុកម្តាយ ឬ ជីដូនជីតា និង សហព័ន្ធរបស់មតកជន អាចផ្ញើលអ្នកម្មនូវទ្រព្យសម្បត្តិ ដូចខាងក្រោមនេះ

ក-១ ភាគ ៣ (មួយភាគបី) នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីដែលមាន តែសន្តតិជនជាឪពុកម្តាយ ឬ ជីដូន ជីតាប៉ុណ្ណោះ ។

២-ក្នុងករណីដែលមានសន្តតិជនច្រើននាក់ អ្នកមានសិទ្ធិលើភាគបម្រុងនីមួយៗ អាចទទួលភាគបម្រុង តាមសមាមាត្រនៃចំណែកមតិកបាន

៣-បញ្ញត្តិនៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) និង មាត្រា ១១៥៨ (ចំណែកមតិក ក្នុងករណីនៃសន្តតិកម្មជំនួស) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះភាគបម្រុង ។

**មាត្រា ១២៣១.. ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង**

១-ភាគបម្រុង ត្រូវគណនាដោយយកទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ ផ្តើមធ្វើសន្តតិកម្ម បូកតម្លៃនៃផលប្រយោជន៍ពិសេស ដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមតិករបស់អ្នកទទួលផលប្រយោជន៍ពិសេស) និង តម្លៃនៃទ្រព្យសម្បត្តិប្រទានកម្ម ដែលបានកំណត់ក្នុងមាត្រា ១២៣២ (ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគ បម្រុង) នៃក្រមនេះ ហើយដកនូវចំនួនប្រាក់សរុបនៃកាតព្វកិច្ចចេញ ។

២-សិទ្ធិដែលភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌ ឬ សិទ្ធិដែលអំឡុងពេលមានអត្ថិភាពមិន ច្បាស់លាស់ ត្រូវកំណត់តម្លៃនោះ ដោយផ្អែកតាមការវាយតម្លៃរបស់អ្នកវាយតម្លៃ ដែលត្រូវបានជ្រើសតាំងដោយតុលាការ ។

៣-កាតព្វកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវរាប់បញ្ចូល ផងដែរ នូវសោហ៊ុយបុណ្យសពតាមឋានៈរបស់មតកជន

**មាត្រា ១២៣២.. ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង**

១-ប្រទានកម្មដែលបានកំណត់ដូចខាងក្រោមនេះ ត្រូវក្លាយជាមូលដ្ឋានក្នុងការ គណនាភាគបម្រុង លើកលែងតែផលប្រយោជន៍ពិសេស ដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមតិករបស់អ្នកទទួលផលប្រយោជន៍ពិសេស) នៃក្រមនេះ

ក- ប្រទានកម្មដែលបានធ្វើក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ នៅមុនពេលចាប់ ផ្ដើមសន្តតិកម្ម ។

ក្រៅពីប្រទានកម្មដែលបានកំណត់ក្នុងចំណុច ក ខាងលើនេះ ប្រទានកម្ម ដែលត្រូវបានធ្វើឡើង ដោយភាគីសងខាងបានដឹងថា នឹងបណ្ដាល ឱ្យខូចខាតដល់អ្នកមាន សិទ្ធិលើភាគបម្រុង

២-នៅក្នុងជំពូកទី ៤ (ភាគបម្រុង) នេះ ការលើកលែងកាតព្វកិច្ចដោយមិនយក តម្លៃថ្នូរ ត្រូវចាត់ទុកថាជាប្រទានកម្ម ។

**មាត្រា ១២៣៣.. ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង អច្ច័យទាន**

ការកំណត់ចំណែកមតិកតាមមតកសាសន៍ ការទទួលផលប្រយោជន៍ ពិសេស និង ប្រទានកម្មដែលបានកំណត់នៅក្នុងមាត្រា ១២៣២ (ប្រទានកម្មដែលជា ក្នុងការគណនាភាគបម្រុង) ខាងលើនេះ គឺជាកម្មវត្ថុនៃការកាត់បន្ថយដើម្បី បង្គ្រប់ភាគបម្រុង ។ ប៉ុន្តែ ក្នុងករណីដែលអច្ច័យទានចំពោះសន្តតិជន ការកំណត់ចំណែក មតិក និង ការទទួលផលប្រយោជន៍ពិសេស ត្រូវក្លាយជាកម្មវត្ថុនៃការកាត់បន្ថយដើម្បី បង្គ្រប់ភាគបម្រុង កម្មវត្ថុនៃការកាត់បន្ថយនោះ បានត្រឹមតែផ្នែកដែលលើសពីចំនួនទឹក ប្រាក់នៃភាគបម្រុងរបស់សន្តតិជននោះប៉ុណ្ណោះ ។

**មាត្រា ១២៣៤.. ចំនួនទឹកប្រាក់នៃការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង**

ចំនួនទឹកប្រាក់ដែលអ្នកមានសិទ្ធិលើភាគបម្រុងអាចទាមទារបានដោយការកាត់ បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺជាចំនួនទឹកប្រាក់ដែលត្រូវបានគណនា ដោយយកចំនួន ទឹកប្រាក់នៃភាគបម្រុង ដកចំនួនសរុបនៃទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិលើភាគបម្រុង បានទទួលដោយសន្តតិកម្ម និង ចំនួននៃផលប្រយោជន៍ពិសេស ហើយបូកបញ្ចូលនូវ ចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលបុគ្គលនោះត្រូវទទួលបន្ទុកដោយសន្តតិកម្ម ។

**មាត្រា ១២៣៨.. លំដាប់នៃការកាត់បន្ថយប្រទានកម្ម ជាអាទិ៍**

១-ការកាត់បន្ថយប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេស ត្រូវចាប់ផ្ដើម ពីប្រធានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើក្រោយគេ បន្ទាប់មកត្រូវ ធ្វើចំពោះប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើពីមុនមកជាបន្តបន្ទាប់ ។

២-បើបានធ្វើប្រទានកម្ម ឬ ទទួលផលប្រយោជន៍ពិសេស លើសពី ២០ (ម្ភៃ) ឆ្នាំ នៅមុនពេលចាប់ផ្ដើមសន្តតិកម្ម បដិគ្គាហក ឬ សន្តតិជនដែលបានទទួលផលប្រយោជន៍ សសនោះអោចបដិសេធនូវការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ។

**មាត្រា ១២៤៥... អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយ**

សិទ្ធិទាមទារឱ្យកាត់បន្ថយ ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ១ (មួយ) ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានដឹងអំពីការចាប់ ផ្ដើមសន្តតិកម្ម និង ការកំណត់ចំណែកមតិក អច្ច័យទាន ប្រទានកម្ម ឬ ការទទួលផល ប្រយោជន៍ពិសេសដែលត្រូវកាត់បន្ថយ ។ សិទ្ធិទាមទារឱ្យកាត់បន្ថយ ក៏ត្រូវរលត់ដោយ អាជ្ញាយុកាល បើអំឡុងពេល ៥ (ប្រាំ) ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលចាប់ផ្ដើម សន្តតិកម្ម ។

**មាត្រា ១២៤៨.អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់**

១-សន្តតិជន ត្រូវធ្វើការយល់ព្រម ឬ ការបោះបង់សន្តតិកម្ម ទាំងស្រុង ឬ ដោយ កម្រិត នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះ ខ្លួន បានចាប់ផ្ដើម ។ ប៉ុន្តែ អំឡុងពេលនេះ អាចពន្យារទៀតបាន តាមពាក្យសុំរបស់សន្តតិជនទៅតុលាការ ។

២-សន្តតិជន អាចធ្វើការស្រាវជ្រាវមត៌កបាន នៅមុនពេលធ្វើការយល់ព្រម ឬ ការបោះបង់ ។

**មាត្រា ១២៥៤.ការយល់ព្រមទាំងស្រុង**

បើសន្តតិជនបានយល់ព្រមទាំងស្រុង ត្រូវទទួលបន្តដោយគ្មានកម្រិត នូវសិទ្ធិ និង កាតព្វកិច្ចរបស់មតកជននោះ ។

**មាត្រា ១២៥៦.ការយល់ព្រមដោយពេនកម្រិត**

១- សន្តតិជនអាចយល់ព្រម ដោយបម្រុងទុកនូវសិណងកាតព្វកិច្ច និង អេច្ច័យមានរបស់មតកជនបាន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម តែ ប៉ុណ្ណោះ ។

-បើសន្តតិជនមានច្រើននាក់ ការយល់ព្រមដោយកម្រិតនេះ អាចធ្វើបាន លុះត្រាតែសហសន្តតិជននោះបានធ្វើដោយរួមគ្នាទាំងអស់ ។

**មាត្រា ១២៥៧. វិធីនៃការយល់ព្រមដោយកម្រិត**

សន្តតិជនដែលមានបំណងចង់យល់ព្រមដោយកម្រិត ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ ហើយត្រូវដាក់ពាក្យសុំអំពីការយល់ព្រមដោយកម្រិតនោះ ទៅតុលាការ នៅក្នុងអំឡុងពេល ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ។

**មាត្រា ១២៥៨.. អានុភាពនៃការយល់ព្រមដោយកម្រិត**

១-ក្នុងករណីដែលសន្តតិជន បានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជន ពុំអាចតាមទាបមារឱ្យសន្តតិជនទទួលខុសត្រូវ ចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ សន្តតិជននោះបានឡើយ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ សិទ្ធិ និង កាតព្វកិច្ច របស់សន្តតិជនដែលមានចំពោះមតកជននោះ ត្រូវចាត់ទុកថាមិនបានរលត់ដោយព្យាកុលភាពឡើយ

## អនុក្រឹត្យលេខ ១០៣ អនក្រ.បក
## ស្តីពីអត្រានុកូលដ្ឋាន

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និង គ្រួសារ ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៥៦ ក្រ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៨៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងយុត្តិធម៌
- តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០០

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

## ជំពូកទី ៤

## អំពីសំបុត្រកំណើត

មាត្រា ១៧ ._

បើមានទារកកើត ឪពុក ឬ ម្តាយ មានភាពព្វកិច្ចត្រូវទៅរាយការណ៍ ចុះសៀវភៅកំណើតនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នៅសាលាឃុំ ឬ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុកម្តាយទារកនោះ មិនអោយហួស៣០ថ្ងៃ ដោយបញ្ជាក់អោយបានច្បាស់ថា ឪពុកនិងម្តាយនៃទារកនោះមានខាន់ស្លា ឬ ឥតខាន់ស្លា ។ បើមានខាន់ស្លាត្រូវបង្ហាញសំបុត្រអាពាហ៍ពិពាហ៍របស់ឪពុក និង ម្តាយទារកនោះ ។

បើឪពុក ម្តាយមានធុរៈទៅមិនបាន ត្រូវពឹងពាក់អ្នកជាសាច់ញាតិសន្តាន ឬ អ្នកនៅជិតខាងដែលបានឃើញ និងដឹងច្បាស់ពីទារកនោះកើតអោយទៅចុះសៀវភៅកំណើតអោយបានទាន់ពេលកំណត់ ដោយយកសំបុត្រអាពាហ៍ពិពាហ៍ ឪពុក និងម្តាយទារកនោះជាប់ទៅជាមួយផង ។

# ច្បាប់
## ស្ដីពី
## អន្តោប្រវេសន៍

### ជំពូកទី ១
### បទបញ្ញត្តិទូទៅ

មាត្រា ១ .-

ច្បាប់នេះមានគោលដៅគ្រប់គ្រងជនបរទេសគ្រប់រូប ដែលមកស្នាក់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ .-

ត្រូវចាត់ទុកជាជនបរទេស ជនណាដែលគ្មានសញ្ជាតិជាខ្មែរ ដោយគ្មានបែងចែក ទោះបីជននោះមានសញ្ជាតិ ជំនឿ សាសនា ឬមានដើមកំណើតណាមួយក៏ដោយ ។

# ច្បាប់

# ស្តីពី

# ការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស

---

**ព្រះរាជក្រម**

នស/រកម/០៥១០/០០៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតក្ខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**ប្រកាសឱ្យប្រើ**

ច្បាប់ ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

**មាត្រា ៤.-**

វាក្យស័ព្ទដែលប្រើក្នុងច្បាប់នេះមាននិយមន័យដូចតទៅ :

- **ជនបរទេស** សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលបរទេសដែលមិនមានសញ្ជាតិខ្មែរ ទោះបីជាបុគ្គលនោះមានសញ្ជាតិ ជំនឿ សាសនា ឬ មានដើមកំណើតពីពូជសាសន៍ណាមួយក៏ដោយ ដោយគ្មានការរើសអើង ។

- **ជនបរទេសដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់** សំដៅដល់ជនបរទេសដែលមានសមត្ថភាពតាមច្បាប់កម្ពុជា និង បានចូលមកព្រះរាជាណាចក្រកម្ពុជាដោយស្របច្បាប់ ។

- **អគារសហកម្មសិទ្ធិ** សំដៅដល់អគារ ឬ សំណង់ដែលមានកម្មសិទ្ធិករច្រើននាក់រស់នៅ ។ អគារសហកម្មសិទ្ធិ មានចំណែកខ្លះជាកម្មសិទ្ធិផ្ដាច់មុខរបស់សហកម្មសិទ្ធិករនីមួយៗហៅថា " ចំណែកឯកជន " និង មានចំណែកខ្លះជាលំហរួម សម្រាប់ការប្រើប្រាស់រួមរបស់សហកម្មសិទ្ធិករទាំងអស់ហៅថា " ចំណែករួម " ។

- **ចំណែកឯកជន** សំដៅដល់ចំណែកនៃអគារសហកម្មសិទ្ធិដែលស្ថិតក្រោមការកាន់កាប់ និង ប្រើប្រាស់ជាឯកជនផ្ដាច់មុខ ។

- **សហកម្មសិទ្ធិករលើចំណែកឯកជន** សំដៅដល់បុគ្គលដែលមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជន ។

- **ចំណែករួម** សំដៅដល់រាល់ចំណែកនៃអគារសហកម្មសិទ្ធិដែលត្រូវចាត់ជាកម្មវត្ថុសម្រាប់ការប្រើប្រាស់ ឬ ជាប្រយោជន៍នៃសហកម្មសិទ្ធិករទាំងអស់ មានជាអាទិ៍ ដី ទីធ្លា ជណ្ដើរ ជិប្អូល ឧទ្យាននិងសួនច្បារ ផ្លូវ ច្រកចេញចូល ជញ្ជាំងអន្តរសិទ្ធិ ទីកន្លែងនៃសេវាកម្មរួម ។

- **សហកម្មសិទ្ធិពិសេស** សំដៅដល់សិទ្ធិរបស់បុគ្គលច្រើនរូបជាជនបរទេស និង ជាពលរដ្ឋខ្មែរលើអគារសហកម្មសិទ្ធិតែមួយ ដែលក្នុងនោះជនបរទេសនិងពលរដ្ឋខ្មែរមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជន និង មានសិទ្ធិកម្មសិទ្ធិអវិភាគពិសេសលើចំណែករួមនៃអគារសហកម្មសិទ្ធិ ។

- **សហកម្មសិទ្ធិករពិសេស** សំដៅដល់ជនបរទេសដែលមានសិទ្ធិសហកម្មសិទ្ធិពិសេស ។

- **កម្មសិទ្ធិអវិភាគពិសេស** សំដៅដល់សិទ្ធិរបស់បុគ្គលច្រើនរូបលើចំណែករួមនៃអគារសហកម្មសិទ្ធិ ដែលក្នុងនោះជនបរទេសមានសិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើចំណែករួម ហើយពលរដ្ឋខ្មែរមានសិទ្ធិកម្មសិទ្ធិអវិភាគលើចំណែករួម ដោយសារមានកម្មសិទ្ធិលើចំណែកឯកជន ។

## ជំពូកទី ២

## គោលការណ៍ទូទៅ

**មាត្រា ៥.-**

ជនបរទេសដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់ មានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ និង សិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើចំណែករួម និងមានកាតព្វកិច្ចគោរពតាមបញ្ញត្តិទាំងឡាយនៃច្បាប់នេះ និង បទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាធរមាន ។

**មាត្រា ៦.-**

ជនបរទេសមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ ចាប់ពីជាន់ទី ១ ( មួយ ) ឡើងទៅ ។ ជាន់ផ្ទាល់ដី និង ជាន់ក្រោមដី មិនត្រូវបានអនុញ្ញាតឱ្យជនបរទេសមានសិទ្ធិកម្មសិទ្ធិឡើយ ។

ចំពោះអគារសហកម្មសិទ្ធិមួយកន្លែង សមាមាត្រ និង របៀបគិតគូរនៃចំណែកឯកជនដែលអាចជាកម្មសិទ្ធិរបស់ជនបរទេសត្រូវកំណត់ដោយអនុក្រឹត្យ ។

ការផ្ដល់កម្មសិទ្ធិនេះ គឺផ្ដល់តែលើចំណែកឯកជននៃអគារសហកម្មសិទ្ធិតែប៉ុណ្ណោះ ។ ចំពោះចំណែករួមនៃអគារសហកម្មសិទ្ធិ ត្រូវរក្សាទុកសម្រាប់សហកម្មសិទ្ធិករទាំងអស់ នៅក្នុងអគារសហកម្មសិទ្ធិប្រើប្រាស់ជារួម ។

ក្នុងករណីណាក៏ដោយ ក៏ក្បាលដីដែលអគារសហកម្មសិទ្ធិតាំងនៅ មិនអាចជាកម្មវត្ថុនៃកម្មសិទ្ធិរបស់សហកម្មសិទ្ធិករពិសេសបានឡើយ ។

ជនបរទេស មិនត្រូវបានអនុញ្ញាតឱ្យ មានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលស្ថិតនៅក្នុងចំងាយ ៣០ ( សាមសិប ) គីឡូម៉ែត្រ ពីព្រំដែនគោកឡើយ និង តំបន់មួយចំនួនទៀត ដែលកំណត់ដោយរាជរដ្ឋាភិបាល លើកលែងតែអគារសហកម្មសិទ្ធិស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ទីប្រជុំជនសំខាន់ៗ និង តំបន់ផ្សេងទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល ។

ក្នុងករណីដែលអគារសហកម្មសិទ្ធិសាងសង់នៅលើដីជួលពីបុគ្គលទី ៣ ជនបរទេសមានសិទ្ធិជួលអចិន្ត្រៃយ៍លើចំណែកឯកជនដូចពលរដ្ឋខ្មែរដែរ ។

# ច្បាប់

# ស្ដីពី

# អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម

រៀបចំចងក្រងដោយ លោក ឡោ ក្រឹម

ឆ្នាំ២០២៣


សេចក្ដីកំណត់
ចំពោះមាត្រានីមួយៗនៃ
ក្រមរដ្ឋប្បវេណី

ភាគ ៣ : គន្ថីទី ៥

រៀបចំដោយ
គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី
និង
ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី

ក្រសួងយុត្តិធម៌

ភ្នំពេញ ២០១០

www.elibraryofcambodia.org